សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ ក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវ ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ៖ លោក **គីម ច័ន្ទរឿន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ **គីម ច័ន្ទរឿន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម L4C5 ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមឆ្លៀតឱកាសដ៏មានតម្លៃនេះ សម្ដែងនូវគារវកិច្ច និងសេចក្ដីដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ៖

**លោកឪពុក ជៀម ចាន់នាង និងអ្នកម្ដាយ ញ៉េម សុខគាង** ដែលរូបលោកទាំងពីរបានផ្ដល់កំណើត ព្រមទាំងលះបង់នូវកម្លាំងកាយចិត្ត ខិតខំតស៊ូជម្នះរាល់ឧបសគ្គនានាក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅកូនតាំងពីតូចរហូតដល់ធំ និងបានបញ្ជូនកូនមកសិក្សាដល់ថ្នាក់ឧត្ដមសិក្សានៅសាកលវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ មហាគុណដែលលោកឪពុកអ្នកម្ដាយបានផ្ដល់ឲ្យកូន ពិតជាមានតម្លៃមិនអាចកាត់ថ្លៃ និងគ្មានអ្វីអាចប្រៀបផ្ទឹមបានឡើយ។

**លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិក** ដែលកំពុងបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ហាត់បង្ហាញ និងណែនាំដល់រូបខ្ញុំបាទតាំងពីឆ្នាំសិក្សាមូលដ្ឋាន រហូតដល់មានឱកាសបានសរសេរសារណាបញ្ចប់ថ្នាក់សិក្សាក្នុងឆ្នាំទី៤នេះ។

ជាពិសេស **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** សាស្ត្រាចារ្យណែនាំ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្ដល់ជាមតិយោបល់ អនុសាសន៍ និងគំនិតសម្រាប់ជាមូលដ្ឋានក្នុងការវិភាគប្រកបដោយគតិបណ្ឌិត ក្នុងការដឹកនាំការសរសេរសារណារបស់ខ្ញុំបាទរហូតសម្រេចទទួលបានជោគជ័យ។

សូមលើកហត្ថាបង្គំវន្ទា សូមបុណ្យបារមីវត្ថុស័ក្តិសិទ្ធិ ម្ចាស់ទឹក ម្ចាស់ដី ទេវតាដែលថែរក្សានៅក្នុងចក្រវាលទាំងមូល សូមលោកជួយបីបាច់ថែរក្សាលោកឪពុកអ្នកម្ដាយ ព្រមទាំងអ្នកមានគុណទាំងឡាយ សូមឲ្យជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន សុខភាពល្អ សំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អស់រយៈពេល ៤ឆ្នាំ ដែលខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយទទួលបាននូវការបណ្តុះបណ្តាលពីសំណាក់លោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យដ៏មានទេពកោសល្យ រហូតធ្វើឲ្យខ្ញុំបាទទទួលបានលទ្ធផលល្អប្រសើរ ឈានមកដល់ការសរសេរសារណាដើម្បីបញ្ចប់ការសិក្សារបស់ខ្លួន។ មុនពេលចាប់ផ្តើមសរសេរសារណានេះ ខ្ញុំបាទបានធ្វើការស្វែងយល់អំពីប្រធានបទមួយចំនួន ដែលពាក់ព័ន្ធនឹងបញ្ហាសង្គមកម្ពុជាបច្ចុប្បន្ន ជាពិសេសបញ្ហាមួយចំនួន ដែលជាបញ្ហាដ៏រសើបហើយរាជរដ្ឋាភិបាលកម្ពុជាបាន នឹងកំពុងតែខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយចំពោះបញ្ហានោះ។ ដោយមើលឃើញថា បញ្ហាចរាចរណ៍នៅតែជាចំណុចអាទិភាពសម្រាប់ការស្វែងរកដំណោះស្រាយក្នុងរាជធានីភ្នំពេញទើបខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទដែលពាក់ព័ន្ធនឹង " **ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ** " ព្រមជាមួយក្តីសង្ឃឹមយ៉ាងមុតមាំថាដំណោះស្រាយដែលខ្ញុំបាទនឹងលើកឡើងនៅក្នុងសារណានេះ ប្រាកដនឹងក្លាយជាចំណុចវិជ្ជមានសម្រាប់ផ្តល់ជាចំណេះដឹងដល់មិត្តៗ និស្សិតអ្នកអានទាំងអស់គ្នាជាក់ជាមិនខាន។

ក្នុងគោលបំណងអភិវឌ្ឍស្នាដៃសិក្សាស្រាវជ្រាវមួយនេះឲ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀតនោះ ខ្ញុំបាទសូមសម្តែងនូវសេចក្តីសោមនស្ស រីករាយ និងស្វាគមន៍ជានិច្ចពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវទាំងអស់ ចំពោះការ ផ្តល់មតិរិះគន់កែលម្អ ទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ ដែលខ្ញុំបាទជឿជាក់ថា អត្ថបទនិពន្ធនីមួយៗអាចកើតមានកំហុសឆ្គងដោយពិបាកនឹងចៀសផុត។

*សូមអរគុណ!*

# មាតិកា ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**បញ្ហាគកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ**

**១.១ ស្ថានភាពទូទៅនៃរាជធានីភ្នំពេញ** ........ ៥

១.១.១ អំពីទីតាំងរាជធានីភ្នំពេញ ........ ៥

១.១.២ ស្ថានភាពសេដ្ឋកិច្ចរាជធានីភ្នំពេញ ........ ៥

១.១.៣ បច្ចុប្បន្នភាពយានយន្ត និងកំណើនប្រជាជន ........ ៥

១.១.៤ ទិដ្ឋភាពគតិយុត្តពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍ ........ ៧

**១.២ កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍** ........ ៨

១.២.១ កត្តាយានយន្ត ........ ៩

១.២.២ កត្តាផ្លូវថ្នល់ ........ ១០

១.២.៣ កត្តាមនុស្ស ........ ១០

១.២.៣.១ ការមិនគោរពភ្លើងសញ្ញាចរាចរណ៍ ........ ១១

១.២.៣.២ ការមិនគោរពផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ ........ ១១

១.២.៣.៣ ការជិះបញ្ច្រាសរបស់អ្នកបើកបរ ........ ១២

១.២.៣.៤ ការប្រើប្រាស់ទូរសព្ទក្នុងពេលបើកបរ ........ ១២

១.២.៣.៥ ការមិនគោរពសិទ្ធិអាទិភាព ........ ១៣

១.២.៣.៦ ការបិទផ្លូវ ........ ១៣

១.២.៣.៧ ការរំលោភលើចិញ្ចើមផ្លូវ ........ ១៤

**១.៣ គុណវិបត្តិនៃការកកស្ទះចរាចរណ៍** ........ ១៤

១.៣.១ ខាតពេលវេលា ........ ១៤
១.៣.២ បញ្ហាសតិអារម្មណ៍ ........ ១៥
១.៣.៣ ខាតសេដ្ឋកិច្ចជាតិ ........ ១៥

## ជំពូកទី២

## ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

**២.១ ទីតាំងកកស្ទះចរាចរណ៍** ........ ១៦
២.១.១ ចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ ........ ១៦
២.១.២ ចំណុចកកស្ទះចរាចរណ៍នៅតាមផ្សារ ........ ១៧
**២.២ ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍** ........ ១៧
២.២.១ ការអប់រំ និងផ្សព្វផ្សាយ ........ ១៧
២.២.២ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពានអាកាស ........ ១៨
២.២.៣ ការរៀបចំមធ្យោបាយធ្វើដំណើរសាធារណៈ ........ ២០
២.២.៣.១ រថយន្តក្រុង ........ ២០
២.២.៣.២ រថភ្លើងអាកាស ........ ២២
២.២.៣.៣ ស្ពានអាកាសថ្មើរជើង ........ ២២
២.២.៣.៤ ការដឹកជញ្ជូនតាមផ្លូវទឹក ........ ២៣
២.២.៤ ការកាត់បន្ថយចំនួនយានយន្ត ........ ២៤
២.២.៥ ការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព និងទំនួលខុសត្រូវ ........ ២៥
២.២.៦ ការចូលរួមរបស់ប្រជាពលរដ្ឋ ........ ២៦
**២.៣ វិធានការអនុវត្តចំពោះបញ្ហាកកស្ទះចរាចរណ៍** ........ ២៨

២.៣.១ ការណែនាំ និងចាត់វិធានការចំពោះបញ្ហាសណ្តាប់ធ្នាប់តាមដងផ្លូវ................. ២៨

២.៣.២ ការប្រើប្រាស់កម្លាំងជាក់ស្តែង .......................................................................៣១

២.៣.៣ អំពីភារកិច្ចរបស់នគរបាលចរាចរណ៍ .......................................................... ៣២

២.៣.៤ បញ្ហាប្រឈមរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ .............................. ៣៤

**សេចក្តីសន្និដ្ឋាន**.......................................................................................................៣៦

**អនុសាសន៍**.............................................................................................................៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

រាជធានីភ្នំពេញ គឺជារាជធានីមួយដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរច្រើនជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នយោបាយ និងវប្បធម៌ជាតំបន់បេតិកភណ្ឌមានអំណោយផលពីធម្មជាតិ ដោយមានប្រាសាទអង្គរវត្តនៅភាគខាងលិច ឆ្នេរសមុទ្រដ៏ស្រស់ស្អាតនៅភាគខាងត្បូង និងដើមកំណើតជនជាតិភាគតិចនៅបណ្តាខេត្តជាច្រើននៃភាគឦសានប្រទេស។ ក្រឡេកពីអតីតកាលបន្តិចវិញនោះ រាជធានីភ្នំពេញបានឆ្លងកាត់សម័យកាលសង្គ្រាមរ៉ាំរ៉ៃ ស្នាមភ្នក់ភ្លើងនៃការឈឺចាប់របស់ប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានគេជម្លៀសចេញទៅជនបទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយរបបប្រល័យពូជសាសន៍ដ៏ខ្មៅងងឹងមួយនេះបានបន្សល់ឲ្យរាជធានីភ្នំពេញទាំងមូលនូវស្ថានភាពស្ងាត់ជ្រងំ ក្លាយទៅជាទីក្រុងខ្មោច ដែលមានផ្ទះតែគ្មានមនុស្សរស់នៅ មានផ្លូវតែគ្មានមនុស្សដើរ។ ក្រោយពីការទទួលជ័យជម្នះ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩មក រាជធានីភ្នំពេញត្រូវបានរៀបចំស្ថាបនាសារជាថ្មី ដោយខិតខំប្រឹងប្រែងក្រាញ់ននៀលចេញពីភ្នក់ភ្លើងសង្គ្រាមស៊ីវិល ព្រមទាំងបន្តក្រោកឈរឡើងដោយដៃទទេ រហូតវិវត្តខ្លួនក្លាយជាទីប្រជុំជនដែលមានមនុស្សរស់នៅកុះករ សម្បូរទៅដោយភ្ញៀវទេសចរ និងទិដ្ឋភាពវប្បធម៌គួរជាទីមោទកភាពសាកសមនឹងឈ្មោះជា"ទីក្រុងគុជនៅក្នុងអាស៊ី"។ លំនឹងនៃស្ថិរភាពនយោបាយរយៈពេលយូរដែលកម្ពុជាមិនដែលទទួលបានជាយូរមកហើយនោះ បានលេចចេញមកគ្របដណ្តប់ទូទាំងប្រទេស ជាមួយនឹងសុខុមាលភាពសង្គម ដោយកម្ពុជាបានអនុវត្តនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស រួមទាំងការធ្វើទំនើបកម្មលើស្ថានភាពគតិយុត្តកម្ពុជាធ្វើយ៉ាងណាធានាបានការទាក់ទាញវិនិយោគទុន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

ស្របពេលដែលកម្ពុជាកំពុងតែបោះជំហានអភិវឌ្ឍបន្តិចម្តងៗនោះ ការទាមទារឲ្យមានការធ្វើកំណែទម្រង់លើគ្រប់វិស័យ ដើម្បីកសាងសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ សង្គមសេដ្ឋកិច្ចបង្កើតបានជាបរិយាកាសរឹងមាំ ដើម្បីទាក់ទាញវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស ក្នុងគោលដៅធានាឲ្យបាននូវកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ដោយសារតែភាពសម្បូរសប្បាយ និងមានមុខងារជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ធំជាងគេនៅកម្ពុជាបែបនេះហើយទើបពីមួយឆ្នាំទៅមួយឆ្នាំ មានប្រជាពលរដ្ឋរាប់សែននាក់បានធ្វើចំណាកស្រុកមកកាន់ទីក្រុងភ្នំពេញដើម្បីបន្តការសិក្សា និងស្វែងរកការងារធ្វើ ដែលបណ្តាលឲ្យទីក្រុងភ្នំពេញមានសភាពអ៊ូអរ ព្រមទាំងមានចរាចរណ៍មមាញឹកជារៀងរាល់ថ្ងៃ។ កាតាលីករដែលបណ្តាលមកពីកំណើនប្រជាពលរដ្ឋ ការរីកចម្រើននៃបច្ចេកវិទ្យា និងតម្រូវការរបស់ប្រជាជនកាន់តែច្រើនទៅៗ ធ្វើឲ្យរាជធានីភ្នំពេញកំពុងតែ

ជួបប្រទះនឹងបញ្ហាជាច្រើនដូចជា បញ្ហាសំរាម បញ្ហាប្រព័ន្ធលូ និងបញ្ហាចរាចរណ៍ជាដើម តួយ៉ាង បញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ បានកំពុងក្លាយទៅជាបញ្ហាដ៏ក្តៅគគុកមួយសម្រាប់ការវិភាគរបស់អ្នកតាមដានសង្គម ក៏ដូចជាបានក្លាយទៅជាចំណុចអាទិភាពរបស់សាលារាជធានីភ្នំពេញក្នុងការដាក់វិធានការស្វែងរកដំណោះស្រាយឲ្យមានប្រសិទ្ធិភាព និងទាន់ពេលវេលា។

ជាការពិតណាស់ ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញតែងតែងនាំគ្នាលើកឡើងអំពីកង្វល់របស់ពួកគេពាក់ព័ន្ធនឹងបញ្ហាកកស្ទះចរាចរណ៍ ដែលបណ្តាលឲ្យពួកគេខាតពេលវេលាធ្វើការរកស៊ី ប្រកបមុខរបរនានា និងអាចបង្កជាផលប៉ះពាល់ដល់សុខភាពរបស់ពួកគេថែមទៀតផង។ ចំពោះបញ្ហានេះសំណួរជាច្រើនត្រូវបានលើកឡើងជាប្រធានបទនៃការពិភាក្សាក្នុងសិក្ខាសាលា និងវេទិកានានាថា តើកត្តាអ្វីខ្លះដែលបានបណ្តាលឲ្យរាជធានីភ្នំពេញប្រឈមមុខនឹងបញ្ហាកកស្ទះចរាចរណ៍? តើដំណោះស្រាយសមស្របណាមួយ ដែលត្រូវយកមកអនុវត្តក្នុងការដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នាពេលបច្ចុប្បន្ននេះ?

### ក. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទដែលបានធ្វើការសិក្សាស្រាវជ្រាវខាងលើនេះ មានគោលបំណងបង្ហាញឲ្យឃើញអំពីបញ្ហាកកស្ទះចរាចរណ៍ដែលបានកើតឡើងនៅក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន ហើយអាចនឹងបន្តក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរសម្រាប់អនាគត ប្រសិនបើយើងមិនបានស្វែងរកដំណោះស្រាយសមស្របណាមួយក្នុងពេលឥឡូវនេះ។ នៅក្នុងន័យនេះ អត្ថបទទាំងមូលក៏បានរំលេចឲ្យឃើញផងដែរអំពីដំណោះស្រាយរបស់ថ្នាក់ដឹកនាំក្នុងការទប់ស្កាត់ការរីករាលដាលនៃបញ្ហាកកស្ទះចរាចរណ៍នេះ ព្រមទាំងវិធានការនៃការអនុវត្តធ្វើយ៉ាងណាធានាឲ្យលិខិតបទដ្ឋានពាក់ព័ន្ធនឹងចរាចរណ៍ផ្លូវគោកត្រូវបានគោរពត្រឹមត្រូវព្រមទាំងមានប្រសិទ្ធិភាពជាទីបំផុត។ ផ្អែកលើការស្រាវជ្រាវ ចំណេះដឹងទាំងអស់នេះប្រាកដជាផ្តល់នូវចំណុចវិជ្ជមានជាច្រើនដល់អ្នកសិក្សា ជាពិសេសបញ្ញវន្តដែលជាអ្នកសិក្សាផ្នែកនីតិសាស្ត្រ ដើម្បីធ្វើការវិភាគ ពិចារណានិងចូលរួមជាគំនិតក្នុងការស្ថាបនាចំណុះខ្វះខាតនានាដែលស្ថាប័នពាក់ព័ន្ធកំពុងអនុវត្តនៅក្នុងក្របខណ្ឌប្រទេសកម្ពុជា។

### ខ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ឆ្លើយតបទៅនឹងទិដ្ឋភាពជាក់ស្តែងនៃប្រធានបទខាងលើនេះ ទំហំនៃការស្រាវជ្រាវនឹងលើកយកមកបង្ហាញពីទិដ្ឋភាពនានាដែលពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍ ការអនុវត្តតាមផែនការដំណោះស្រាយរបស់អាជ្ញាធរនៅក្នុងរាជធានីភ្នំពេញ និងដំណោះស្រាយទូទៅដ៏សមស្របមួយដែលយើងទទួលបានបន្ទាប់ពីការសិក្សាផ្សេងៗ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវវិញ សារណាមួយច្បាប់នេះត្រូវបានធ្វើការស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ដោយខ្ញុំបាទបានចុះស្រាវជ្រាវរកឯកសារនៅក្នុងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងសាលារាជធានីភ្នំពេញ។

**គ. សារៈសំខាន់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានចាត់ទុកថាជាការរួមចំណែកនៅក្នុងការអភិវឌ្ឍសង្គមកម្ពុជា ដោយផ្តល់នូវពុទ្ធិចំពោះមិត្តៗអ្នកអាន និងមានខ្លឹមសារដាស់តឿនចំពោះប្រជាពលរដ្ឋកម្ពុជាឲ្យធ្វើការកែប្រែឥរិយាបថក្នុងការរស់នៅ ជាពិសេសឥរិយាបថក្នុងការបើកបរប្រកបដោយទំនួលខុសត្រូវ ដោយត្រូវតែយកចិត្តទុកដាក់ចំពោះការអនុវត្តច្បាប់ និងគិតគូរពីផលប្រយោជន៍អ្នកដទៃ ចៀសវាងការបើកបរដោយគ្មានការអត់អោន អធ្យាស្រ័យ និងក្លាយជាប្រជាពលរដ្ឋដែលមានភាពអាត្មានិយម។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋត្រូវតែមានស្មារតីរំលឹកខ្លួនឯងថា ខ្លួនជាចំណែកមួយនៃសង្គមដែលចាំបាច់ត្រូវតែចូលរួមទាំងអស់គ្នាក្នុងការរៀបចំសង្គមកម្ពុជាក្លាយជាប្រទេសដែលមានសណ្តាប់ធ្នាប់ និងភាពស្រស់បំព្រង។

**ឃ. វិធីសាស្ត្រក្នុងការស្រាវជ្រាវ**

ដោយសារតែប្រធានបទខាងលើនេះជាប្រធានបទមួយដែលមានលក្ខណៈរសើបនិងជាបញ្ហាមួយដែលបាននឹងកំពុងតែចោទឡើងនៅក្នុងទិដ្ឋភាពសង្គមកម្ពុជា ទើបធ្វើឲ្យការសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធជួបប្រទះនឹងការលំបាកខ្លះៗ ដោយមូលហេតុថា មិនទាន់មានឯកសារគោលណាមួយបានបង្ហាញអំពីគោលគំនិត និងដំណោះស្រាយជាក់លាក់នៅក្នុងចំណោទបញ្ហានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការរៀបចំសៀវភៅសារណាមួយក្បាលនេះ ខ្ញុំបាទបានខិតខំព្យាយាមដោយពឹងពាក់ទៅលើអ្វីដែលជាការសិក្សាទ្រឹស្តី ជាមូលដ្ឋានគំនិតនៃការវិភាគពិចារណាលើទស្សនៈក្នុងលិខិតបទដ្ឋានគតិយុត្តនិងបញ្ហាក្នុងសង្គម ការសិក្សាស្វែងរកឯកសារតាមបណ្ណាល័យ បណ្ណាគារ ស្ថាប័នរដ្ឋ រួមជាមួយនឹងការចែករំលែកបទពិសោធន៍ពីសំណាក់សាស្ត្រាចារ្យ មន្ត្រីជំនាញផ្សេងៗល។ ក្រៅពីការស្វែងរកប្រភពឯកសារជាប្រភេទ Hard Ware ខាងលើនេះ ខ្ញុំក៏បានស្វែងរកឯកសារពាក់ព័ន្ធនានាផ្សេងៗទៀតផងដែរ ក្នុងនោះមានឯកសារក្នុងប្រព័ន្ធអ៊ីនធើណេត ការបង្ហាញគំនិតតាមប្រព័ន្ធសង្គម និងសារព័ត៌មាននានាជាដើម។

**ង. រចនាសម្ព័ន្ធនៃប្រធានបទ**

ឆ្លើយតបទៅនឹងគោលបំណងនៃការសរសេរសារណារបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ខ្ញុំបាទបានធ្វើការបែងចែករចនាសម្ព័ន្ធសារណាដូចខាងក្រោម៖

- **ជំពូកទី១ បញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ ៖** ក្នុងជំពូកនេះនឹងលើកឡើងអំពីស្ថានភាពទូទៅនៃរាជធានីភ្នំពេញ កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍

និងគុណវិបត្តិនៃការកកស្ទះចរាចរណ៍។

- **ជំពូកទី២ ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ៖** ក្នុងជំពូកនេះនឹងលើកឡើងអំពីទីតាំងកកស្ទះចរាចរណ៍ ដំណោះស្រាយចរាចរណ៍ និងវិធានការអនុវត្តចំពោះបញ្ហាចរាចរណ៍។

# ជំពូកទី១

# បញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

# ជំពូកទី១

# បញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

## ១.១ ស្ថានភាពទូទៅក្នុងរាជធានីភ្នំពេញ

ភ្នំពេញ ជាទីក្រុងរាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា ហើយជាទីក្រុងដែលធំជាងគេនៅក្នុងប្រទេសកម្ពុជាដែលមានចំនួនប្រជាពលរដ្ឋជិត២លាននាក់នៅក្នុងឆ្នាំ២០១៧។ ភ្នំពេញត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលធ្វើជំនួញ ពាណិជ្ជកម្ម ឧស្សាហកម្ម និងមានបណ្តុំសំណង់អាគារធំៗជាច្រើន រួមបញ្ចូលទាំងទីផ្សារ និងផ្សារទំនើបដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះ គេឃើញមានសកលវិទ្យាល័យធំៗនានា ព្រលានយន្តហោះអន្តរជាតិ កំពង់ផែផ្លូវទឹក និងមធ្យោបាយធ្វើដំណើរផ្លូវគោកសម្រាប់ផ្គត់ផ្គង់ការដឹកជញ្ជូន និងផ្ទុកទំនិញផ្សេងៗ និងជាកន្លែងទេសចរណ៍ដែលទាក់ទាញភ្ញៀវជាតិ-អន្តរជាតិបានច្រើនជាងគេបន្ទាប់ពីខេត្តសៀមរាប។

### ១.១.១ ទីតាំងរាជធានីភ្នំពេញ

រាជធានីភ្នំពេញស្ថិតនៅតំបន់ខាងត្បូងភាគកណ្តាលនៃប្រទេសកម្ពុជា ដែលព័ទ្ធជុំវិញទៅដោយខេត្តកណ្តាល ស្ថិតនៅលើច្រាំងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់។ រាជធានីភ្នំពេញមានព្រំប្រទល់ខាងលិចទល់នឹងស្រុកអង្គស្នួល ខាងកើតទល់នឹងស្រុកកៀនស្វាយ ខាងជើងទល់នឹងស្រុកមុខកំពូល ខាងត្បូងទល់នឹងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ បច្ចុប្បន្ននេះ រាជធានីភ្នំពេញមាន៖

- ផ្ទៃដីសរុបចំនួន ៦៩២,៦៤ គីឡូម៉ែតក្រឡា និងចំនួនប្រជាជនសរុប ១.៤៦១.៨៥៣ នាក់
- ចំនួន ១២ ខណ្ឌ ១០៥ សង្កាត់ ភូមិចំនួន ៩៥៣ និងមាន២៨៩.៥៥៨ គ្រួសារ[1]។

### ១.១.២ ស្ថានភាពសេដ្ឋកិច្ចរាជធានីភ្នំពេញ

ដោយរាជធានីភ្នំពេញត្រូវបានចាត់ទុកថាជាតំបន់ស្នូលនៃសេដ្ឋកិច្ចកម្ពុជា ដូច្នេះចំពោះផ្នែកសេដ្ឋកិច្ចនេះ ខ្ញុំបាទសូមធ្វើការដកស្រង់អត្ថបទទាំងស្រុងតាមរបាយការណ៍ប្រចាំឆមាសនៅក្នុងគេហទំព័រផ្លូវការរបស់ធនាគារពិភពលោក ដោយបានបង្ហាញអំពីរបកគំហើញមួយចំនួនពាក់ព័ន្ធនឹងសេដ្ឋកិច្ចនៅកម្ពុជាដូចខាងក្រោម[2]៖

- ក្នុងឆ្នាំ២០១៦ កំណើនសេដ្ឋកិច្ចបន្តមានសម្ទុះខ្លាំងនៅឡើយគឺមាន ៧ភាគរយ។ ប៉ុន្តែសម្រាប់ឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថាថមថយបន្តិចមកនៅត្រឹម ៦,៨ភាគរយ។

---

[1] រដ្ឋបាលរាជធានីភ្នំពេញ, ២០១៨, *របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ*, លេខ០២០

[2] http://www.worldbank.org/km/country/cambodia/publication/cambodia-economic-update-october-2017 (ថតចម្លងនាថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៨)

- ការនាំចេញសំលៀកបំពាក់ និងផលិតផលវាយនភណ្ឌផ្សេងទៀត មានសម្ទុះមធ្យម រីឯវិស័យសំណង់វិញក៏កំពុងតែបង្ហាញសញ្ញាឲ្យឃើញថាមានសភាពថមថយដែរ។ ជាការប៉ះប៉ូវដល់ការធ្លាក់ចុះក្នុងការនាំចេញសំលៀកបំពាក់ និងផលិតផលវាយនភណ្ឌ គេឃើញមានការកើនឡើងនៃចំណែកការនាំចេញផលិតផលមិនមែនវាយនភណ្ឌ ជាពិសេសគ្រឿងអេឡិចត្រូនិកបរិក្ខារ និងគ្រឿងបន្លាស់យានយន្ត នៅពេលដែលប្រទេសកម្ពុជាកំពុងបោះជំហានឈានឡើងនៅក្នុងខ្សែសង្វាក់តម្លៃវិស័យកម្មន្តសាល។
- កិច្ចប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាដើម្បីទាក់ទាញភ្ញៀវទេសចរហាក់ដូចជាទទួលបានលទ្ធផល ដោយគេឃើញមានការងើបឡើងគួរឲ្យកត់សម្គាល់នូវចំនួនមកដល់របស់ទេសចរបរទេស។
- អតិផរណានៅរក្សាសភាពមធ្យម ដែលឆ្លុះបញ្ចាំងឲ្យឃើញថាតម្រូវការប្រើប្រាស់ក្នុងស្រុកមានភាពថមថយ នៅពេលដែលកំណើនក្នុងផ្នែកសំណង់បានបង្ហាញសញ្ញាធ្លាក់ល្បឿន ហើយសម្ទុះកំណើនឥណទានក្នុងស្រុកក៏ស្រុតចុះបន្តិចវិញដែរ។
- ទន្ទឹមគ្នានេះដែរ ស្ថានភាពនៅខាងក្រៅរក្សាបានលំនឹង ដោយក្នុងនោះ ឱនភាពគណនេយ្យចរន្តកាន់តែរួមតូច ហើយទុនបម្រុងអន្តរជាតិសរុបបានកើន ជាសមមូល ស្មើនឹង៦ខែ នៃទំហំតម្លៃរបស់ការនាំចេញ។
- ឱនភាពសារពើពន្ធជារួម ត្រូវបានប្រមាណឃើញថារក្សាបានស្ថានភាពដដែល ដោយសារការប្រមូលចំណូលបានល្អ។ ការកើនឡើងទំហំវិក្កយបត្របៀវត្សរ៍ក្នុងវិស័យសាធារណៈត្រូវបានប៉ះប៉ូវដោយការធ្លាក់ចុះនូវការចំណាយមូលធនដែលទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយ។
- ទស្សនវិស័យទៅមុខនៅមានភាពវិជ្ជមាន។ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករទុកថានឹងមានសម្ទុះរឹងប៉ឹង ក្នុងកម្រិត៦,៩ភាគរយ ក្នុងឆ្នាំ២០១៨ ដោយសារតែពិពិធកម្មក្នុងការនាំចេញ ការរក្សាស្ថានភាពល្អនៃការហូរចូលទុនវិនិយោគផ្ទាល់មកពីខាងក្រៅ និងការប្រមើលទុកថាស្ថានភាពសេដ្ឋកិច្ចសាកលនឹងមានភាពកាន់តែប្រសើរ។
- យ៉ាងណាក៏ដោយ លទ្ធភាពដែលអាចមានការធ្លាក់ចុះកំណើនសេដ្ឋកិច្ចក្នុងតំបន់ ជាពិសេសសេដ្ឋកិច្ចប្រទេសចិន និងភាពមិនប្រាកដប្រជាពាក់ព័ន្ធជាមួយការបោះឆ្នោត អាចបង្កហានិភ័យដល់ទស្សនវិស័យសម្រាប់កំណើននេះដែរ។

**១.១.៣ បច្ចុប្បន្នភាពយានយន្ត កំណើនប្រជាជន**

រយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ច៧%ជារៀងរាល់ឆ្នាំ ដែលកំណើនសេដ្ឋកិច្ចបែបនេះ បានធ្វើឲ្យជីវភាពប្រជាពលរដ្ឋដែលមានចំណូលកម្រិតមធ្យមមានសភាពប្រសើរឡើង ពោលគឺគ្រប់ក្រុមគ្រួសារនីមួយៗមានលទ្ធភាពស្វែងរកចំណូលដើម្បីទិញរថយន្ត

ឯកជនផ្ទាល់ខ្លួនយកមកប្រើប្រាស់បាន។ កំណើនតម្រូវការប្រើប្រាស់រថយន្តនៅកម្ពុជាមានការកើនឡើងបែបនេះ ជាកត្តាសំខាន់ធ្វើឲ្យក្រុមហ៊ុនរថយន្តល្បីៗមួយចំនួនបានដាក់ការចាប់អារម្មណ៍មកលើទីផ្សារកម្ពុជា។ បច្ចុប្បន្ននេះ កម្ពុជាបាននាំចូលរថយន្តស្ទើរតែគ្រប់ប្រភេទដើម្បីបំពេញតម្រូវការក្នុងស្រុក ដែលភាគច្រើននាំចូលមកពីប្រទេសដែលជាដៃគូដូចជា ជប៉ុន ថៃ ចិន កូរ៉េខាងត្បូង សហរដ្ឋអាមេរិក និងបណ្តាលប្រទេសមួយចំនួនទៀតនៅសហភាពអឺរ៉ុប។

យោងតាមស្ថិតិរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន នៅក្នុងឆ្នាំ២០១៧ រាជធានីភ្នំពេញមានរថយន្តគ្រប់ប្រភេទសរុបចំនួន ៤៤២.៩៧២ គ្រឿង និងចំនួនទោចក្រយានយន្តគ្រប់ប្រភេទមានចំនួន១.៦០១.៤៥១គ្រឿង[3]។

ក្នុងឱកាសប្រារព្ធពិធីបុណ្យឆ្លងឆ្នាំសកលឆ្នាំ២០១៧ ឈានចូលឆ្នាំ២០១៨ នៅរមណីយដ្ឋានវត្តភ្នំ ឯកឧត្តម ឃួន ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានលើកឡើងថា " រហូតដល់បច្ចុប្បន្ននេះ រាជធានីភ្នំពេញមានការអភិវឌ្ឍគ្រប់វិស័យ ពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មសាធារណៈ សំណង់ គ្រឹះស្ថាន អគារនានា នៅក្នុងរាជធានីភ្នំពេញ បានចាប់ផ្តើមមានការអភិវឌ្ឍ ឆ្លើយតបនឹងកំណើនប្រជាជនទីក្រុង ដែលកើនឡើងយ៉ាងឆាប់រហ័ស រហូតដល់៣,២៥% ក្នុងមួយឆ្នាំៗ។ បច្ចុប្បន្ននេះ ចំនួនប្រជាជននៅរាជធានីភ្នំពេញ បានកើនឡើងរហូតដល់១,៧លាននាក់ ក្នុងនោះមានប្រមាណ៥៦% ជាប្រជាជន ជាអ្នកចំណាកស្រុក ចូលមកសិក្សា និងធ្វើការនៅក្នុងទីក្រុងភ្នំពេញ" [4] ។

### ១.១.៤ និដ្ឋភាពគតិយុត្តពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍

នៅក្នុងអំឡុងមុនឆ្នាំ១៩៩៣ កម្ពុជាមិនទាន់បានរួចផុតពីបញ្ហាសង្គ្រាមស៊ីវិលផ្ទៃក្នុងនោះទេ ជាមូលហេតុដែលធ្វើឲ្យរាជធានីភ្នំពេញមានសភាពស្ងប់ស្ងាត់ មិនសូវមានយានយន្តច្រើនធ្វើដំណើរនោះទេ ហើយជាក់ស្តែងសូម្បីតែបញ្ហាកកស្ទះចរាចរណ៍ក៏មិនទាន់បានកើតមានឡើងនោះឡើយ។ ប៉ុន្តែក្រោយពីទទួលបាននូវភាពសុខសាន្តពេញលេញ និងការឈានជើងចូលទៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរីរួចមក កម្ពុជាបានអភិវឌ្ឍនូវវិស័យជាច្រើនដូចជា វិស័យពាណិជ្ជកម្ម រោងចក្រ សហគ្រាស វិស័យអប់រំ ទូរគមនាគមន៍ កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសការធ្វើឲ្យវត្តមាននៃការធ្វើវិនិយោគរបស់បរទេសមកកម្ពុជាសំដៅមករាជធានីភ្នំពេញ ជាកត្តាបង្កឲ្យរាជធានីភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

ទន្ទឹមនឹងការរីកចម្រើនផ្នែកបច្ចេកវិទ្យា ការនាំចូលយានយន្តគ្រប់ប្រភេទដើម្បីបម្រើតម្រូវការ

[3] www.dad-news.com (ចតចម្លង នាថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៨)

[4] www.Phnompenh.gov.kh (ចតចម្លង នាថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨)

របស់ប្រជាពលរដ្ឋ ព្រមទាំងការកើនឡើងជាបន្តបន្ទាប់ឥតដាច់នៃកំណើនប្រជាជននៅក្នុងរាជធានីភ្នំពេញផងនោះ បានធ្វើឲ្យរាជធានីភ្នំពេញត្រូវប្រឈមនឹងបញ្ហាចរាចរណ៍ជារៀងរាល់ថ្ងៃ។ បញ្ហាចរាចរណ៍នោះត្រូវបានគេកត់សម្គាល់ឃើញតាមរយៈគ្រោះថ្នាក់ចរាចរណ៍ ការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ការបើកបរលើសល្បឿនកំណត់ និងកត្តាជាច្រើនទៀត ហើយអ្វីដែលបានចោទឡើងជាបញ្ហាក្នុងអំឡុងមួយរយៈពេលចុងក្រោយនេះ គឺបញ្ហាកកស្ទះចរាចរណ៍ដែលបណ្តាលឲ្យប្រជាពលរដ្ឋមានការថ្នាំងថ្នាក់ជាខ្លាំង។ បញ្ហាមួយនេះ មិនត្រឹមតែបានបង្កជាកង្វល់សម្រាប់ប្រជាពលរដ្ឋទូទៅនោះទេ ប៉ុន្តែវាថែមទាំងបានបង្កជាបន្ទុកទៅដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ដែលមានតួនាទីធ្វើយ៉ាងណាស្វែងរកដំណោះស្រាយដើម្បីឲ្យបញ្ហានោះមានភាពល្អប្រសើរឡើងវិញ។

ឆ្លើយតបទៅនឹងបញ្ហាដែលបានកើតឡើងឥតឈប់ឈរនេះ គេឃើញមានលិខិតបទដ្ឋានគតិយុត្តជាច្រើនបានប្រតិដ្ឋឡើងដើម្បីជារនាំងកំណត់ពីព្រំដែននៃការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងគោលបំណងធានាធ្វើឲ្យសង្គមជាតិទាំងមូលមានការរស់នៅប្រកបដោយភាពចុះសម្រុងនឹងគ្នាមានសន្តិភាព ភាពសុខសាន្ត ជាពិសេសការលប់បំបាត់នូវបញ្ហានានាដែលបានបង្កជាការលំបាកដល់ប្រជាពលរដ្ឋ។ ចំពោះបញ្ហាចរាចរណ៍វិញ យើងឃើញមានច្បាប់ អនុក្រឹត្យ និងសេចក្តីណែនាំជាច្រើនបានលេចចេញជារូបរាងបន្តបន្ទាប់គ្នាដើម្បីធានានូវការគោរពច្បាប់ឲ្យមានប្រសិទ្ធិភាព ជាក់ស្តែងយើងឃើញមានលិខិតបទដ្ឋានសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ច្បាប់ចរាចរណ៍ផ្លូវគោកចុះថ្ងៃទី ០៦ មករា ឆ្នាំ២០១៥ និង ច្បាប់ស្តីពីផ្លូវថ្នល់ចុះថ្ងៃទី ០៤ ឧសភា ឆ្នាំ២០១៤
- ព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។
- អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក។
- ផែនការសកម្មភាព របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ល។

## ១.២ កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍

ស្របពេលដែលរាជធានីភ្នំពេញកំពុងតែមានភាពរីកចម្រើនស្ទើរគ្រប់វិស័យពិតមែនក៏ដោយក៏ចំណុចវិជ្ជមានមួយត្រូវបានលើកឡើងជាផលវិបាកនិងជាកត្តាសំខាន់ដែលរដ្ឋកំពុងតែយកចិត្តទុកដាក់ដោះស្រាយនោះគឺ បញ្ហាកកស្ទះចរាចរណ៍។ ជារៀងរាល់ថ្ងៃ ជាពិសេសនៅពេលម៉ោង

ធ្វើដំណើរទៅធ្វើការ ឬត្រលប់មកពីបំពេញការងារវិញនោះ រាជធានីភ្នំពេញទាំងមូលហាក់បីដូចជាមានភាពអូអាប់ពោលពេញដោយសំឡេងមនុស្សត្រហឹងអឺងកង ព្រមទាំងផ្សែងដែលភាយចេញពីយានជំនិះរបស់ប្រជាពលរដ្ឋបង្កបានជាការបំពុលបរិស្ថានមួយដ៏សម្បើម។

តាមការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាបានឲ្យឃើញពីកត្តាសំខាន់ៗមួយចំនួនដែលបង្កឲ្យមានការកកស្ទះចរាចរណ៍ដូចខាងក្រោម៖

### ១.២.១ កត្តាយានយន្ត

សន្តិភាព និងការអភិវឌ្ឍប្រកបដោយមោទកភាពក្នុងនាមជាម្ចាស់ប្រទេស បានក្លាយជាមូលហេតុបណ្តាលឲ្យវត្តមានរោងចក្រ សហគ្រាសតូចធំជាច្រើនបានកកើតឡើងនៅគ្រប់ទីប្រជុំជននានាក្នុងប្រទេសកម្ពុជា។ ក្នុងនោះដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់នៅក្នុងប្រទេស រោងចក្រ សហគ្រាសនាំចូលនូវមធ្យោបាយធ្វើដំណើរបានធ្វើការនាំចូលមកនូវមធ្យោយបាយដឹកជញ្ជូន និងមធ្យោយបាយធ្វើដំណើរទំនើបជាច្រើនសម្បូរបែប ដែលការកើនឡើងជាបន្តបន្ទាប់នៃចំនួនយានយន្ត និងទោចក្រយានយន្តនេះ ត្រូវបានគេសន្និដ្ឋានថា បណ្តាលមកពីកត្តាជីវភាពរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរឡើង។ ជាក់ស្តែងណាស់ បច្ចុប្បន្ននេះបើយើងគិតពីជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងរង្វង់គ្រួសារនីមួយៗរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ ជាមធ្យមយ៉ាងហោចណាស់ក្នុងមួយគ្រួសារក៏មានរថយន្តចំនួន១គ្រឿងដែរ ហើយខ្លះទៀតមានរហូតទៅដល់២ ឬ ៣ គ្រឿងឯណោះ។ ការកើនឡើងនូវចំនួនយានជំនិះគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញ ដែលកំពុងតែចរាចរណ៍នៅតាមដងវិថីនានានោះ ធ្វើឲ្យទំហំនៃការប្រើប្រាស់ផ្លូវរបស់អ្នកធ្វើដំណើរកាន់តែតូចទៅៗ ដែលជាកត្តាបណ្តាលឲ្យដងវិថីទាំងមូលស្ទើរតែគ្មានកន្លែងសម្រាប់ធ្វើដំណើរជាពិសេសនៅរៀងរាល់ម៉ោងចេញឬចូលបំពេញការងារ។

ម្យ៉ាងវិញទៀតនោះ អ្វីដែលគួរឲ្យកត់សម្គាល់អំពីផ្នត់គំនិតរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការជ្រើសរើសយកប្រភេទរថយន្តសម្រាប់តែការធ្វើដំណើរលក្ខណៈគ្រួសារវិញនោះ គឺពួកគេតែងតែធ្វើការជ្រើសរើសយកប្រភេទរថយន្តដែលមានលក្ខណៈសម្បត្តិចំពោះតែរូបរាងខាងក្រៅ ទំហំ ឬក៏តម្លៃតែប៉ុណ្ណោះ។ ជាទូទៅពួកគាត់មិនបានសម្លឹងឃើញអំពីអត្ថប្រយោជន៍ ស្ថានភាពភូមិសាស្ត្រ ភាពងាយស្រួលនៃការធ្វើដំណើរ ឬការដឹកជញ្ជូនដែលរថយន្តនោះបានផ្តល់មកឲ្យខ្លួនវិញនោះទេ ជាក់ស្តែងរថយន្តដែលមានរូបរាងធំៗ ដូចជាប្រភេទ Lexus, Tuntra ជាដើមនេះ ត្រូវបានចរាចរពាសពេញរាជធានីភ្នំពេញ ដែលតាមពិតទៅប្រភេទរថយន្តទាំងអស់នោះធ្វើឲ្យអ្នកបើកបរជួបប្រទះនឹងបញ្ហាជាច្រើនដូចជា ប្រើប្រាស់ប្រេងឥន្ទនៈលើសពីរថយន្តធម្មតា ពិបាកក្នុងការស្វែងរកកន្លែងចត និងជាផ្នែកមួយក្នុងការចូលរួមឲ្យបញ្ហាកកស្ទះចរាចរណ៍កាន់តែមានភាពស្មុគស្មាញ។

### ១.២.២ កត្តាផ្លូវថ្នល់

ចំពោះរាជធានីភ្នំពេញ ផ្លូវថ្នល់ប្រៀបបាននឹងសរសៃឈាមដែលមិនអាចនឹងខ្វះបាន ហើយបាននឹងកំពុងតែឆ្លើយតបទៅនឹងតម្រូវការដតឈប់ឈររបស់អ្នកធ្វើដំណើរ។ ដោយសារតែកម្ពុជាទើបតែទទួលបានការអភិវឌ្ឍក្រោយពេលដែលបានបញ្ចប់នូវសង្គ្រាមស៊ីវិលនៅក្នុងអំឡុងឆ្នាំ១៩៩៣ ហេតុដូច្នេះហើយ ប្រព័ន្ធគមនាគមន៍មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយនោះទេ។ បើយើងក្រឡេកមើលចំពោះទិដ្ឋភាពនៅក្នុងរាជធានីភ្នំពេញវិញ យើងអាចសង្កេតឃើញថា នៅមានបណ្តាផ្លូវជាច្រើនត្រូវបានសាងសង់ដោយពុំមានស្តង់ដារបច្ចេកទេសច្បាស់លាស់ គ្មានការបំពាក់នូវស្លាកសញ្ញាចរាចរណ៍ឲ្យបានត្រឹមត្រូវ គ្មានការគិតគូរពីទំហំផ្លូវប្រៀបធៀបនឹងស្ថានភាពចរាចរណ៍ដែលកំពុងតែបើកបរជារៀងរាល់ថ្ងៃហើយផ្លូវខ្លះទៀតត្រូវបានខូចខាតក្លាយទៅជាផ្លូវសំបុកមាន់ ដែលទាមទារឲ្យអាជ្ញាធរមានសមត្ថកិច្ចចាំបាច់ត្រូវតែគិតគូរឲ្យបានទាន់ពេលវេលា។ ជាការពិតមែនហើយ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតែដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ហើយបើផ្លូវថ្នល់តូចនោះ អ្នកបើកបរពិតមានភាពលំបាកហើយបង្កជាការកកស្ទះគួរឲ្យធុញទ្រាន់ជាក់ជាមិនខាន ម្យ៉ាងទៀតដោយសារតែប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតែមានទម្លាប់រុលទៅមុខដោយមិនបានគិតគូរពីអ្នកដទៃដែលនៅជុំវិញខ្លួនបែបនេះហើយ ដូច្នេះស្ថានភាពផ្លូវតូចៗមួយចំនួនពិតជាបង្កឲ្យស្ថានភាពកកស្ទះចរាចរណ៍កាន់តែធ្ងន់ធ្ងរទៅពីមួយថ្ងៃទៅមួយថ្ងៃ។

### ១.២.៣ កត្តាមនុស្ស

កត្តាមួយដែលត្រូវបានគេតែងតែលើកឡើងថា ជាកត្តាសំខាន់បំផុតដែលបញ្ហាឲ្យមានការកកស្ទះចរាចរណ៍នោះ គឺឥរិយាបថរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់។ កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះស្ថានភាពនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ តួយ៉ាងបើយើងក្រឡេកទៅមើលក្នុងទិដ្ឋភាពចរាចរណ៍កម្ពុជាវិញ អ្នកបើកបរមួយចំនួនពុំបានយល់ដឹងពីច្បាប់ចរាចរណ៍នោះឡើយ ដោយពួកគេខ្លះគ្មានបណ្ណបើកបរ ខ្លះមិនស្គាល់ពីសិទ្ធិអាទិភាពរបស់ខ្លួននៅលើដងវិថី ខ្លះបើកបរបញ្ច្រាសទិស ខ្លះមិនគោរពភ្លើងសញ្ញាចរាចរណ៍ជាដើម។ ការបើកបរដោយមិនមានទំនួលខុសត្រូវ មិនចេះអធ្យាស្រ័យ និងមិនបានសិក្សាស្វែងយល់ពីផលប៉ះពាល់ដែលខ្លួនយើងម្នាក់ៗអាចនឹងបង្កឲ្យមានការខូចខាត ឬគ្រោះថ្នាក់អ្នកដទៃនោះ បង្កើតឲ្យមានបរិយាកាសអាប់អួរនិងគួរឲ្យស្អប់ខ្ពើមជាទីបំផុតដែលទង្វើនោះមិនគួរឲ្យកើតមានឡើយនៅក្នុងសង្គម។

ចំពោះអ្នកបើកបរវិញ ជាទូទៅយើងមើលឃើញថា ពួកគេបើកបរដោយមិនបានយល់ពីបញ្ហាដូចខាងក្រោម៖

### ១.២.៣.១ ការមិនគោរពភ្លើងសញ្ញាចរាចរណ៍

ភ្លើងសញ្ញាចរាចរណ៍ត្រូវបានគេបង្កើតឡើង ដើម្បីសម្រួលដល់ធ្វើដំណើររបស់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ដោយធ្វើការបែកចែងនូវពេលវេលាត្រឹមត្រូវច្បាស់លាស់ សិទ្ធិអាទិភាពក្នុងការបើកបរ ធ្វើយ៉ាងណាឲ្យសមស្របសម្រាប់ទិសដៅ និងស្ថានភាពទំហំផ្លូវនីមួយៗ។ ភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌លឿង ជាសញ្ញាឲ្យប្រុងប្រយ័ត្ន ត្រៀមឈប់ ពន្លឺពណ៌បៃតង ជាសញ្ញាអនុញ្ញាតឲ្យយានជំនិះចេញដំណើរ ពន្លឺពណ៌ក្រហមជាសញ្ញាឃាត់ឲ្យឈប់ ។ ការបើកបរដោយមិនបានគោរពទៅតាមភ្លើងសញ្ញាចរាចរណ៍ឲ្យបានត្រឹមត្រូវទេនោះ បណ្តាលឲ្យស្ថានភាពដងផ្លូវមានសភាពរញ៉េរញ៉ៃ និងគ្មានសណ្តាប់ធ្នាប់បង្កជាការកកស្ទះចរាចរណ៍ដ៏គួរឲ្យធុញទ្រាន់ជាពន់ពេក។ តាមការសង្កេតមើលជាក់ស្តែង អ្នកបើកបរភាគច្រើនមិនបានប្រុងប្រយ័ត្នមើលភ្លើងសញ្ញា ឬមិនយល់ដឹងអំពីភ្លើងសញ្ញាចរាចរណ៍ ឬបានដឹងហើយប៉ុន្តែតែងតែលើកយកមូលហេតុផ្សេងៗជាច្រើនឥតគណនាមកបំពានលើភ្លើងសញ្ញាទាំងអស់នោះ បើទោះបីជាទង្វើនោះបណ្តាលឲ្យខ្លួនក្លាយជាមនុស្សអាត្មានិយមក៏ដោយ។

### ១.២.៣.២ ការមិនគោរពផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍

ផ្លាកសញ្ញចរាចណ៍ ភ្លើងសញ្ញាចរាចណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ ត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារៈប្រយោជន៍ ដែលធ្វើឲ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ [5] ។ បើទោះបីជាការបំពាក់នូវសញ្ញាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញពុំទាន់ត្រឹមត្រូវបានគ្រប់ជ្រុងជ្រោយក៏ដោយ ប៉ុន្តែសញ្ញាចរាចរណ៍ទាំងអស់នោះបានផ្តល់នូវភាពសមល្មមសម្រាប់អ្នកបើកបរដើម្បីនឹងអនុវត្តហើយក៏ជាការរួមចំណែកដ៏សំខាន់ក្នុងការកាត់បន្ថយការកកស្ទះចរាចណ៍ផងដែរ។ ប៉ុន្តែផ្ទុយមកវិញ អ្នកបើកបរនៅរាជធានីភ្នំពេញបច្ចុប្បន្ននេះ មិនបានគោរពទៅតាមគំនូសសញ្ញា ឬផ្លាកសញ្ញាចរាចរណ៍នោះទេ សូម្បីតែគំនូសសញ្ញាចរាចរណ៍សម្រាប់អ្នកថ្មើរជើងនៅកម្ពុជាបច្ចុប្បន្ននេះ ក៏ត្រូវបានប្រែក្លាយទៅជាចំណតសម្រាប់យានយន្តឈប់រង់ចាំភ្លើងសញ្ញាចរាចរណ៍របស់អ្នកបើកបរនៅតាមដងផ្លូវបាត់ទៅហើយ(មាត្រា១១ កថាខណ្ឌ២ អ្នកបើកបរត្រូវត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវ ឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់)។ ជាការពិតមែនហើយ ការឈប់យានយន្តនៅតាមស្តុបនីមួយៗក្នុងរាជធានីភ្នំពេញបច្ចុប្បន្ននេះ យើងអាចមើលឃើញថា ហាប់បីដូចជាគ្មានសណ្តាប់ធ្នាប់ គ្មានភាពជាជួរ រំលោភលើគន្លងផ្លូវ និងស្នាមគំនូសកាត់ទទឹងទ្រូងផ្លូវ គំនូសអ្នកថ្មើរជើង ដែលបង្កបានជាការកកស្ទះ និងការរិះគន់ច្រើនពីសំណាក់ប្រជាពលរដ្ឋដែលបានគោរពច្បាប់ចរាចរណ៍។ លើសពីនេះទៅទៀតនោះ នៅតាម

[5] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, លេខនស/រកម/០១១៥/០០១, ០៦ មករា ២០១៥, មាត្រា៥ កឋាខណ្ឌទី២ ។

បណ្តាដងវិថីមួយចំនួនមានការចតយានជំនិះជាច្រើនហូរហែ ទាំងដែលនៅតាមដងវិថីទាំងអស់នោះមានផ្លាកសញ្ញាហាមចត ហាមឈប់ ដែលកត្តាទាំងអស់នេះធ្វើឲ្យទំហំផ្លូវកាន់តែរួមតូចបង្កជាបញ្ហាកកស្ទះចរាចរណ៍ស្ទើរតែរាល់ថ្ងៃ។ នៅពេលខ្លះ ស្លាកសញ្ញាចរាចរណ៍ស្ទើរតែគ្មានអត្ថន័យសម្រាប់អ្នកបើកបរនៅក្នុងរាជធានីភ្នំពេញ។

### ១.២.៣.៣ ការជិះបញ្រ្ចាសរបស់អ្នកបើកបរ

ការជិះបញ្រ្ចាសផ្លូវបានក្លាយជាទម្លាប់ដ៏អាក្រក់របស់ប្រជាពលរដ្ឋដែលជាអ្នកបើកបរនៅក្នុងរាជធានីភ្នំពេញ ជាពិសេសនៅពេលដែលស្ថានភាពផ្លូវកំពុងតែមានការកកស្ទះនៅតាមដងវិថីនានានោះ ពួកគាត់បែរជាធ្វើការសម្រេចចិត្តជិះបញ្រ្ចាសផ្លូវ ជិះចូលគន្លងផ្លូវរបស់អ្នកដទៃ ធ្វើយ៉ាងណាឲ្យតែយានជំនិះរបស់ពួកគាត់បានរុលទៅមុខ និងដល់ទិសដៅ ដោយមិនខ្វល់ពីស្ថានភាពចរាចរណ៍នឹងទៅជាយ៉ាងណានោះទេ។ កត្តានេះ មិនត្រឹមតែធ្វើឲ្យពួកគាត់កាន់តែខាតពេលវេលានោះទេ ថែមទាំងបានបង្កឲ្យស្ថានភាពផ្លូវម្ខាងទៀតនោះមានការកកស្ទះលើសដើម ហើយជួនកាលអាចនឹងបង្កឲ្យគ្រោះថ្នាក់ចរាចរណ៍ប៉ះពាល់ដល់អាយុជីវិតអ្នកដទៃថែមទៀតផង។ ករណីពាក់ព័ន្ធនឹងករណីជិះបញ្រ្ចាសនេះ យោងតាមរបាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នៅក្នុងរយៈពេល៣ខែនៃដើមឆ្នាំ២០១៨នេះ លទ្ធផលត្រួតពិនិត្យចរាចរណ៍បានបង្ហាញថា បានចាប់ឃាត់យានយន្តសរុបចំនួន៥១.៣៨៦ គ្រឿង ក្នុងនោះមានទោចក្រយានយន្តចំនួន៤៩.១៣៧គ្រឿង ម៉ូតូរ៉ឺម៉ក់និងកង់បីចំនួន១៦៣គ្រឿង រថយន្តចំនួន២.០៨៦ គ្រឿង ដោយឡែកក្នុងនោះមានម៉ូតូបើកបញ្រ្ចាសទិសចំនួន១៤.៨១៥គ្រឿង ម៉ូតូរ៉ឺម៉ក់និងកង់បើកបញ្រ្ចាសចំនួន១៦៣គ្រឿង(គោលដៅវិមានឯករាជ្យ) និងរថយន្តបើកបញ្រ្ចាសមានចំនួន៨៩គ្រឿង។

### ១.២.៣.៤ ការប្រើប្រាស់ទូរសព្ទក្នុងពេលបើកបរ

ប្រជាពលរដ្ឋកម្ពុជាចូលចិត្តណាស់ចំពោះការប្រើប្រាស់ទូរសព្ទដៃទំនើបៗ ថែមទាំងពេលខ្លះពួកគេចាត់ទុកថា វាជារឿងដ៏លំបាកប្រសិនបើធ្វើដំណើរទៅណាមកណាដោយគ្មានទូរសព្ទជាប់ជាមួយខ្លួនទេនោះ។ ប៉ុន្តែការប្រើប្រាស់ទូរសព្ទក្នុងខណៈពេលបើកបរត្រូវបានច្បាប់កំណត់មិនឲ្យប្រើប្រាស់នោះទេ ករណីគ្មានឧបករណ៍ភ្ជាប់សំឡេង។ អំឡុងមួយរយៈពេលក្រោយនេះ គេសង្កេតឃើញថា អ្នកបើកបរនៅរាជធានីភ្នំពេញមួយចំនួន តែងតែងប្រើប្រាស់ទូរសព្ទចូលទៅកាន់ហ្វេកបុកហ្គេម ឬនិយាយទូរសព្ទគ្រប់ពេលវេលា ដែលទង្វើទាំងអស់នេះធ្វើឲ្យអ្នកបើកបរបាត់ការផ្តោតអារម្មណ៍លើដងវិថី ដែលបណ្តាលឲ្យយានយន្តមានលក្ខណៈវេចង្កូត ឆ្វេង ស្តាំជារឿយៗដែលអាចនឹងបង្កជាបញ្ហាដល់អ្នកដទៃហើយនាំឲ្យមានការកកស្ទះចរាចរណ៍ផងដែរ។

### ១.២.៣.៥ ការមិនគោរពសិទ្ធិអាទិភាព

នៅពេលដែលយើងនិយាយអំពីពាក្យថា អាទិភាព យើងសំដៅទៅលើសិទ្ធិដែលអ្នកបើកបរអាចនឹងទទួលបានមុនគេនៅក្នុងស្ថានភាពផ្លូវធ្វើដំណើរពេលកំពុងបើកបរ។ សិទ្ធិអាទិភាព ជាកត្តាសំខាន់ដែលអ្នកបើកបរចាំបាច់ត្រូវតែទទួលការយល់ដឹងអំពីការប្រើប្រាស់ផ្លូវរបស់ខ្លួន ថាតើការប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់ខ្លួនតាមដងផ្លូវនោះ វាប៉ះពាល់ ឬបំពានសិទ្ធិអ្នកដទៃដែលឬទេ? ឧទាហរណ៍ ករណីនៅពេលដែលអ្នកកំពុងបើកបរនៅក្នុងផ្លូវលំក្នុងទិសដៅកែងគ្នានឹងមហាវិថីធំៗនោះ នៅពេលដែលដល់ចំណុចប្រសព្វគ្នា អ្នកចាំបាច់ត្រូវធ្វើការបន្ថយល្បឿន និងទុកសិទ្ធិអាទិភាពឲ្យយានយន្តដែលកំពុងតែចរាចរនៅលើផ្លូវធំនោះ ចេញដំណើរទៅមុន រួចទើបអ្នកមានសិទ្ធិបើកចេញទៅតាមក្រោយ។ នេះជាការអនុវត្តទៅតាមផ្លូវច្បាប់ ហើយអ្វីដែលបានលើកឡើងខាងលើនេះសុទ្ធតែជាចំណុចតូចៗ ដែលបច្ចុប្បនេះប្រជាពលរដ្ឋ អ្នកបើកបរកំពុងតែប្រើប្រាស់មធ្យោបាយធ្វើដំណើរទាំងបំពានលើសិទ្ធិអាទិភាពរបស់អ្នកដទៃ មិនចេះយោគយល់ មិនចេះបន្ថយល្បឿនឲ្យយានជំនិះផ្សេងគេទៅមុននោះទេ គិតតែពីភាពប្រញាប់ប្រញាល់របស់ខ្លួនឯងបង្កបានជាកត្តានាំឲ្យបញ្ហាកកស្ទះចរាចរណ៍ចោទឡើង រហូតពេលខ្លះធ្វើឲ្យអ្នកបើកបរដែលជាមនុស្សថ្លៃថ្នូរ មានមុខមាត់នៅក្នុងសង្គមក្លាយទៅជាមនុស្សអាត្មានិយមមួយរំពេចភ្នែកដោយសារការបើកបររបស់ខ្លួន។

### ១.២.៣.៦ ការបិទផ្លូវ

ការបិទផ្លូវនៅក្នុងស្ថានភាពមួយចំនួនក៏បានបណ្តាលឲ្យអ្នកបើកបរប្រឈមនឹងបញ្ហាកកស្ទះចរាចរណ៍ផងដែរ ហើយជាទូទៅការបិទផ្លូវនោះអាចបណ្តាលមកពីការហែក្បួនអមគណៈប្រតិភូ ពិធីបុណ្យសាសនា ប្រពៃណីជាតិផ្សេងៗ ការធ្វើបាតុកម្ម ឬការតវ៉ានានា ការរៀបចំពិធីបុណ្យឬមង្គលការរបស់ប្រជាពលរដ្ឋជាដើម។ តាមបទពិសោធន៍នៃការមើលឃើញកន្លងមក គ្មាននរណាម្នាក់ហ៊ានមកអះអាងទេថា នៅក្នុងសង្គមនៃការរស់នៅរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ប្រជាពលរដ្ឋនិងថ្នាក់ដឹកនាំបច្ចុប្បន្ននេះ មានលក្ខណៈស្មើគ្នា តម្លាភាព មិនលំអៀងនោះ។ អ្វីទាំងអស់នេះ វាស្តែងចេញពីទង្វើដែលប្រជាពលរដ្ឋមើលឃើញនឹងភ្នែករបស់ពួកគេ ជាក់ស្តែងករណីនៅពេលដែលមានក្បួនហែរគណៈប្រតិភូ ឬអ្នកមានអំណាចធ្វើដំណើរតាមដងវិថីណាមួយ វិថីផ្សេងៗទៀតដែលនៅក្បែរនោះត្រូវបានគេបិទដើម្បីទុកផ្លូវឲ្យទូលាយឲ្យក្បួនហែ ឬឡានរបស់អ្នកមានអំណាចនោះធ្វើចរាចរ ដែលការដែលបិទផ្លូវទាំងនោះនាំឲ្យប្រជាពលរដ្ឋមានការមិនសប្បាយចិត្តដោយសារបង្កឲ្យមានការយឺតយ៉ាវដល់ពួកគេ។ ឆ្លើយតបនឹងបញ្ហាបិទផ្លូវនេះ កាលពីថ្មីៗកន្លងទៅនេះ នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ នៅក្នុងការបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៥ពីព្រែកក្តាមដល់ខេត្តពោធិ៍សាត់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះ

រាជាណាចក្រកម្ពុជាបានថ្លែងសុំទោសប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញដែលត្រូវបិទផ្លូវនៅពេលដែលសម្តេចក៏ដូចជាគណៈប្រតិភូមួយចំនួនធ្វើដំណើរតាមដងផ្លូវ។ សម្តេចលើកឡើងថា "សម្តេចធ្លាប់បានសុំកុំឲ្យមានការបិទផ្លូវពេលសម្តេចឆ្លងកាត់ តែបើមិនបិទផ្លូវអាចស្ទះផ្លូវទៅចូលរួមកិច្ចប្រជុំនានាមិនទាន់"[6]។

### ១.២.៣.៧ ការរំលោភលើចិញ្ចើមផ្លូវ

យោងតាមឯកសាររបស់រដ្ឋបាលរាជធានីភ្នំពេញបានឲ្យដឹងថា ក្នុងមួយរយៈពេលកន្លងបងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅស្ថាន ម្ចាស់សហគ្រាស ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញាត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយដ្ឋាន និងសំណង់។ អំពើរំលោភបំពាននោះស្តែងចេញតាមរូបភាពដូចជា ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុមព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើជាទីតាំងការដ្ឋានទុកដាក់សម្ភារ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្មផ្សេងៗជាលក្ខណៈឯកជនដែលបង្កឲ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ[7]។

## ១.៣ គុណវិបត្តិនៃការកកស្ទះចរាចរណ៍

ជាការពិតណាស់ ករណីដែលយើងមើលទៅតាមស្ថានភាពកកស្ទះម្តងៗ អ្នកបើកបរត្រូវខាតពេលវេលាក្នុងការប្រកបរបររកស៊ី ជំនួញជួញដូរ អាចនឹងត្រូវទទួលរងនូវការស្តីបន្ទោសពីកន្លែងធ្វើការងារ ខកខានការប្រជុំជាមួយថ្នាក់ដឹកនាំរបស់ខ្លួនជាដើម។ តាមរយៈការសិក្សាអង្កេតពីទិដ្ឋភាពជាក់ស្តែង យើងអាចធ្វើការបកស្រាយទៅលើចំណុចអវិជ្ជមានចំនួន៣ ដែលបង្កឡើងដោយបញ្ហាកកស្ទះចរាចរណ៍៖

### ១.៣.១ ខាតពេលវេលា

គ្មាននរណាម្នាក់ដែលចង់ធ្វើដំណើរទៅធ្វើការយឺតនោះហើយឲ្យត្រូវចៅហ្វាយស្តីបន្ទោសនៅកន្លែងបំពេញការងារនោះទេ ប៉ុន្តែនៅពេលខ្លះយើងពិតជាមិនអាចប៉ាន់ស្មានពីការកកស្ទះចរាចរណ៍

---

[6] www.pressocm.gov.kh (ថតចម្លងថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨)

[7] សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ពួនោះទេ។ រឿងជាច្រើនបានកើតឡើងបែបនេះ ផ្លូវធ្វើដំណើរទៅធ្វើបំពេញការងារ បើធ្វើដំណើរទៅនៅពេលយប់ស្ងាត់ឬពេលព្រលឹមស្រាងៗនោះ គេអាចនឹងចំណាយពេលវេលាត្រឹមតែ១៥ទៅ២០នាទីប៉ុណ្ណោះ ប៉ុន្តែប្រសិនបើធ្វើដំណើរក្នុងចន្លោះម៉ោង៧ព្រឹក ឬក៏៥ល្ងាចវិញនោះ គេត្រូវចំណាយពេលវេលា១ម៉ោងទើបទៅដល់កន្លែងបំពេញការងារ។ បច្ចុប្បន្ននេះ ការកកស្ទះចរាចរណ៍ត្រូវបានគេចាត់ទុកថា ជាចោរលួចពេលវេលាដ៏សកម្មដែលបញ្ហានេះពិតជាផ្តល់ផលវិបាកជាពន់ពេកសម្រាប់ប្រជាពលរដ្ឋទូទៅ មន្ត្រីរាជការ និងភ្ញៀវបរទេសដែលចូលមកទស្សនានៅក្នុងរាជធានីភ្នំពេញ។

### ១.៣.២ បញ្ហាសតិអារម្មណ៍

អ្វីដែលគួរឲ្យបារម្ភជាងនេះទៅទៀតនោះ ស្ថានភាពកកស្ទះចរាចរណ៍បណ្តាលឲ្យអ្នកបើកបរមានអារម្មណ៍តានតឹង មួម៉ៅក្នុងចិត្ត ហើយបើបញ្ហានេះបន្តកើតឡើងយូរៗទៅ អាចនឹងបណ្តាលឲ្យប្រជាពលរដ្ឋប្រឈមមុខនឹងបញ្ហាផ្នែកអារម្មណ៍ ដែលបង្កឡើងឲ្យពួកគេក្លាយជាមនុស្សឆេវឆាវ និងគ្មានភាពអធ្យាស្រ័យ។ អ្នកទាំងអស់គ្នា អាចប្រហែលជាយល់ថា អ្វីដែលបានលើកឡើងខាងលើនេះជាការលេងសើច ប៉ុន្តែផ្អែកតាមវេជ្ជបណ្ឌិតផ្នែកចិត្តសាស្ត្របានលើកឡើងថា ជំងឺផ្លូវចិត្តភាគច្រើនបណ្តាលមកពីអាការធុញថប់នឹងអ្វីដែលបានកើតឡើងនៅជុំវិញខ្លួន បញ្ហាខឹងច្រើនបង្កជាក្តៅក្រហាយនៅក្នុងខ្លួន ភាពតានតឹងជាច្រើនដែលបានកើតឡើងជារឿយៗ។ ផ្សាភ្ជាប់នឹងចំណុចនេះ ចុះប្រសិនបើអ្នកបើកបរដែលតែងតែប្រឈមនឹងបញ្ហានេះជារៀងរាល់ថ្ងៃ តើអាចទេថាពួកគេនឹងមានអារម្មណ៍តានតឹង?

### ១.៣.៣ ខាតសេដ្ឋកិច្ចជាតិ

នៅពេលដែលមានបញ្ហាកកស្ទះចរាចរណ៍ តើបុគ្គលិកស្ថាប័នរដ្ឋ និងឯកជនប៉ុន្មានរូបដែលខកខានមិនបានទៅបំពេញការងារ? តើអ្នកលក់ដូរប៉ុន្មានរូបដែលបាត់បង់ចំណូលប្រចាំថ្ងៃរបស់ពួកគេនោះ? គេត្រូវមើលទៅលើបញ្ហាទាំងអស់នេះ ពីព្រោះថាចំណូលប្រជាពលរដ្ឋក៏បានដើរតួនាទីដ៏សំខាន់ក្នុងការទ្រទ្រង់នូវសេដ្ឋកិច្ចប្រទេសជាតិ ដូច្នេះប្រជាពលរដ្ឋបាត់បង់ប្រាក់ចំណូល មានន័យថាសេដ្ឋកិច្ចជាតិក៏ត្រូវបានខាតបង់ផងដែរ។ កាលពីឆ្នាំ២០១៧កន្លងទៅថ្មីៗនេះ ផ្អែកតាមប្រសាសន៍អភិបាលរងរាជធានីភ្នំពេញ លោក អៀង អូននី បានលើកឡើងថា គ្រាន់តែបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញរាល់ថ្ងៃនេះ បានធ្វើឲ្យកម្ពុជាខាតបង់ប្រាក់ដល់ទៅជាងប្រមាណ៦លានដុល្លារក្នុងមួយឆ្នាំ[8]។

[8] www.angkorpost.net (ចតចម្លង នាថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨)

# ជំពូកទី២

# ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

# ជំពូកទី២
# ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

ជាការពិតណាស់ គ្រប់បញ្ហាដែលបានកើតមានឡើងសុទ្ធតែមានដំណោះស្រាយ ប៉ុន្តែតើយើងអាចស្វែងរកដំណោះស្រាយបញ្ហាទាំងនោះដោយវិធីណា? ក្នុងករណីស្វែងរកឃើញហើយ តើមានអ្នកណាខ្លះដែលត្រូវចូលរួមដើម្បីដោះស្រាយបញ្ហានោះ? គ្រប់សំណួរសុទ្ធតែបានបង្កប់អត្ថន័យនៃការស្វែងយល់ឲ្យបានស៊ីជម្រៅអំពីទម្រង់បញ្ហាដែលបានកើតឡើង ដូចជាករណីបញ្ហាកកស្ទះចរាចរណ៍នេះជាដើម យើងទាំងអស់គ្នាចាំបាច់ត្រូវតែស្វែងរកមូលហេតុពិតប្រាកដរបស់វា និងហ៊ានលាតត្រដាងអំពីអ្វីដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុវត្តកន្លងមក ហើយឆ្លុះបញ្ចាំងមើលថាតើវាឆ្លើយតបទៅនឹងដំណោះស្រាយហើយឬយ៉ាងណា?

នៅក្នុងជំពូកនេះ ខ្ញុំបាទនឹងលើកអំពីដំណោះស្រាយបញ្ហាកកស្ទះចរាចណ៍ទូទៅមួយដែលថ្នាក់ដឹកនាំកម្ពុជាបាននឹងកំពុងតែព្យាយាមអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយចាំបាច់ទាមទារឲ្យមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់បងប្អូនប្រជាពលរដ្ឋ អ្នកបើកបរដែលកំពុងតែធ្វើចរាចរណ៍ក្នុងរាជធានីភ្នំពេញ រួមជាមួយនឹងផែនការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញដែលបានអនុវត្តកន្លងមក។

## ២.១ ទីតាំងកកស្ទះចរាចរណ៍

ដើម្បីស្វែងរកដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយនោះសមត្ថកិច្ច និងមន្ត្រីរាជការគ្រប់ស្ថាប័នពាក់ព័ន្ធចាំបាច់ត្រូវតែធ្វើការតាមដានត្រួតពិនិត្យឲ្យបានម៉ត់ចត់ ព្រមទាំងក្តោបព័ត៌មានឲ្យបានទាំងអស់អំពីគោលដៅ និងទីកន្លែងដែលជាអចិន្ត្រៃយ៍រមែងតែងតែជួបប្រទះនឹងបញ្ហាកកស្ទះចរាចរណ៍នោះ។ យោងតាមការពិនិត្យជាក់ស្តែង នៅក្នុងរបាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទីតាំងកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញបច្ចុប្បន្ននេះត្រូវបានគេអង្កេតទៅលើផ្នែកចំនួនពីរ ពោលគឺចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ និងចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារ[៩]។

### ២.១.១ ចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ

តាមរបាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានី ខណ្ឌទាំង១២នៃរាជធានីភ្នំពេញមានចំនុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវមានដូចខាងក្រោម ៖

- ខណ្ឌដូនពេញ ចំនួន ២៧ គោលដៅ

[៩] ផែនការសកម្មភាពស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ, លេខ១១៤ ផ.ក ,២០ កក្កដា ២០១៧

- ខណ្ឌ៧មករា ចំនួន ៣៣ គោលដៅ
- ខណ្ឌចំការមន ចំនួន ៣១ គោលដៅ
- ខណ្ឌទួលគោក ចំនួន ៣២ គោលដៅ
- ខណ្ឌឫស្សីកែវ ចំនួន ០៨ គោលដៅ
- ខណ្ឌជ្រោយចង្វា ចំនួន ០៣ គោលដៅ
- ខណ្ឌព្រែកព្នៅ ចំនួន ០២ គោលដៅ
- ខណ្ឌសែនសុខ ចំនួន ១២ គោលដៅ
- ខណ្ឌពោធិ៍សែនជ័យ ចំនួន ០៧ គោលដៅ
- ខណ្ឌដង្កោ ចំនួន ០៦ គោលដៅ
- ខណ្ឌមានជ័យ ចំនួន ០៦ គោលដៅ
- ខណ្ឌច្បារអំពៅ ចំនួន ០៥ គោលដៅ ។

### ២.១.២ ចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារ

យោងតាមការអង្កេតជាក់ស្តែង ចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះ មានចំនួន ២០ ផ្សារដូចខាងក្រោម៖

- ខណ្ឌដូនពេញ ៖ ផ្សារធំថ្មី ផ្សារចាស់ ផ្សារកណ្តាល ផ្សារសុរិយា ផ្សាររាត្រី
- ខណ្ឌ៧មករា ៖ ផ្សារអូរឫស្សី
- ខណ្ឌចំការមន ៖ ផ្សារអូឡាំពិក ផ្សារទួលទំពូង ផ្សារAEON
- ខណ្ឌទួលគោក ៖ ផ្សារដើមគរ ផ្សារសាមគ្គី ផ្សារហេងលី ផ្សារដេប៉ូ
- ខណ្ឌឫស្សីកែវ ៖ ផ្សារទួលសង្កែ ផ្សារខាំកូ
- ខណ្ឌពោធិ៍សែនជ័យ ៖ ផ្សារពោធិ៍ចិនតុង ផ្សារស៊ិនជូវីផ្លាហ្សា ផ្សារជម្ពូវ័ន្ត
- ខណ្ឌច្បារអំពៅ ៖ ផ្សារច្បារអំពៅ ផ្សារព្រែកឯង។

## ២.២ ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍

### ២.២.១ ការអប់រំ និងផ្សព្វផ្សាយ

ការអប់រំ និងផ្សព្វផ្សាយត្រូវបានចាត់ទុកថាជាកាតាលីកមួយដ៏មានអាទិភាពក្នុងការធានាឲ្យផែនការកាត់បន្ថយការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផលតាមគោលដៅដែលបានកំណត់។ ជាការពិតណាស់ នៅក្នុងការអភិវឌ្ឍសង្គមមួយប្រកបដោយភាពរីកចម្រើន ជាទូទៅគឺគ្មានអ្វីដែលធំធេងជាងការផ្តល់ចំណេះដឹង និងព័ត៌មានដែលត្រឹមត្រូវជូនប្រជាពលរដ្ឋនោះទេ។ ចំពោះបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញអាច

ឲ្យយើងលើកឡើងបានថា ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការបើកបរ និងសារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍នៅមានកម្រិតនៅឡើយ ដូច្នេះក្នុងនាមជាថ្នាក់ដឹកនាំរដ្ឋាភិបាល និងមន្ត្រីរាជការសាធារណៈចាំបាច់ត្រូវតែយកចិត្តទុកដាក់ផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ចរាចរណ៍ ដូចជា ការគោរពគំនូសសញ្ញាចរាចរណ៍ គំនូសអ្នកថ្មើរជើង ផ្លាកចរាចរណ៍ជាដើម។ ការអប់រំនិងផ្សព្វផ្សាយនេះ អាចធ្វើឡើងតាមរយៈការបើកយុទ្ធនាការចែកខិត្តបណ្ណផ្សព្វផ្សាយតាមទីសាធារណៈ ការរៀបចំសិក្ខាសាលាដែលមានការចូលរួមអំពីអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលជាដើម។ ម៉្យាងវិញទៀតនោះ ស្របតាមគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកចំពោះការអប់រំនិងផ្សព្វផ្សាយត្រូវបានកំណត់តាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ការរៀបចំបញ្ចូលក្នុងកម្មវិធីសិក្សាស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងប្រព័ន្ធអប់រំ
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីរៀបចំយុទ្ធនាការសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ដែលងាយរងគ្រោះ និងឥរិយាបថដែលនាំទៅរកគ្រោះថ្នាក់ចរាចរណ៍
- ជំរុញការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- ជំរុញការផ្សព្វផ្សាយ និងអប់រំសុវត្ថិភាពចរាចរណ៍នៅតាមផ្លូវថ្នល់ និងនៅតាមសហគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា [10]។

### ២.២.២ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពានអាកាស

ស្ថិតនៅក្នុងស្ថានភាពប្រទេសកំពុងអភិវឌ្ឍ ប្រទេសកម្ពុជាចាំបាច់បន្តនិរន្តរភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ព្រមទាំងធានាឲ្យបាននូវគុណភាពក្នុងការរៀបចំគម្រោងផែនការនីមួយៗ។ នៅក្នុងក្របខណ្ឌនេះ រដ្ឋាភិបាលមានកាតព្វកិច្ចធានាឲ្យការរៀបចំផ្លូវថ្នល់តាមទីប្រជុំជននីមួយៗមានលក្ខណៈត្រឹមត្រូវតាមស្តង់ដារ លុបបំបាត់អំពើពុករលួយគ្រប់រូបភាពដែលអាចនឹងបណ្តាលឲ្យសំណង់ផ្លូវថ្នល់មិនធានាបានគុណភាពដើម។ លើសពីនេះទៅទៀត រដ្ឋាភិបាលចាំបាច់ត្រូវតែយកចិត្តទុកដាក់បំផុតចំពោះការបំពេញហេដ្ឋារចនាសម្ព័ន្ធដែលកំពុងតែខ្វះខាត និងព្យាយាមធ្វើយ៉ាងណាកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នៅតាមផ្លូវចំណុចប្រសព្វនានាឲ្យខានតែបាន។ ចំពោះបញ្ហាភ្លើងសញ្ញាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញវិញនោះ លោក សាំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ទទួលបន្ទុកគម្រោងដំឡើងភ្លើងស្តុបក្នុងរាជធានី

[10] គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, សៀវភៅគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក, (២០១៤), ចំណុចទី៤

ភ្នំពេញលើកឡើងថា " ការដំឡើងស្តុបថ្មីនៅរាជធានីភ្នំពេញ ដើរដោយប្រព័ន្ធ Smart Signal អាចជួយសម្រួលដល់ចរាចរណ៍នៅតំបន់កកស្ទះ ហើយអ្វីដែលសំខាន់ទៀតនោះ គេអាចបញ្ជាភ្លើងស្តុបចេញពីបន្ទប់ត្រួតពិនិត្យផ្ទាល់យ៉ាងងាយស្រួល ហើយពាក់ព័ន្ធនឹងភ្លើងស្តុបដំណើរការនៅលើមហាវិថីធំពីរ គួយ៉ាង មហាវិថីព្រះមុនីវង្ស និងមហាវិថីនរោត្តម គេឃើញមានភ្លើងស្តុបជាច្រើន ដាក់បញ្ឈរកៀកៗគ្នា ក្នុងរយៈចម្ងាយប្រហែល ១គីឡូម៉ែត្រ មានស្តុបមួយយ៉ាងហោចណាស់ "[11]។

ក្រៅពីនេះ ក្រោមជំនួយរបស់ក្រសួងសន្តិសុខសាធារណៈចិន កម្ពុជាបានបំពាក់កាមេរ៉ាត្រួតពិនិត្យចរាចរណ៍នៅតាមស្តុបមួយចំនួនដែលក្នុងនោះទីតាំងនីមួយៗត្រូវបានបំពាក់កាមេរ៉ាគ្រប់គ្រងចរាចរណ៍ចំនួន០៨កាមេរ៉ា។ ខាងក្រោមនេះ ជាទីតាំងស្តុបដែលនឹងត្រូវបំពាក់កាមេរ៉ាត្រួតពិនិត្យចរាចរណ៍៖

- ស្តុបច្រមុំជ្រូកក្បាលថ្នល់ នៅតាមបណ្តោយផ្លូវព្រះមុនីវង្ស
- ស្តុបក្រសួងមហាផ្ទៃ នៅតាមបណ្តោយមហាវិថីព្រះនរោត្តម កែងផ្លូវលេខ ៤៨៤
- ស្តុបចំការមន នៅតាមបណ្តោយព្រះនរោត្តម កែងមហាវិថីម៉ៅសេទុង
- ស្តុបបូកគោ នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីម៉ៅសេទុង
- ស្តុបពេទ្យចិន នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីព្រះសីហនុ
- ស្តុបទូតអាឡឺម៉ង់ នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវលេខ ២១៤
- ស្តុបអូរឫស្សី នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវលេខ ១៨២
- ស្តុបផ្សារធំថ្មី នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវលេខ ២១៧
- ស្តុបសួនកាណាឌីយ៉ា នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីសហព័ន្ធរុស្ស៊ី
- ស្តុបសណ្ឋាគារណានជីង នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងផ្លូវលេខ ១៣៩
- ស្តុបដេអិន នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងផ្លូវលេខ ១៦៩
- ស្តុបវិទ្យាល័យសន្ធរម៉ុក នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងមហាវិថីម៉ៅសេទុង
- ស្តុបទេពផន នៅតាមបណ្តោយមហាទេពផន កែងមហាវិថីម៉ៅសេទុង
- ស្តុបម៉ុងឌីយ៉ាល់ នៅតាមបណ្តោយមហាវិថីម៉ៅសេទុង កែងផ្លូវលេខ ២៣០
- ស្តុបអាងទឹកស្តាតអូវឡាំពិក នៅតាមបណ្តោយមហាវិថីព្រះមុន្នីវ៉េត កែងមហាវិថីព្រះសីហនុ
- ស្តុបនាងគង្ហីង រង្វង់មូលនាងគង្ហីង
- ស្តុបផ្សារដេប៉ូ នៅតាមបណ្តោយវិថី កែងផ្លូវលេខ ២១៥

[11] https://urbanvoicecambodia.net (ថតចម្លងនាថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៨)

- ស្តុបច្បារអំពៅ ២ នៅតាមបណ្តោយផ្លូវជាតិលេខ១

បន្ថែមពីនេះទៅទៀតនោះ បន្ទាប់ពីបញ្ហាកកស្ទះចរាចរណ៍កាន់តែមានភាពធ្ងន់ធ្ងរទៅពីមួយថ្ងៃទៅមួយថ្ងៃនោះ សំណង់ស្ពានអាកាសត្រូវបានប្រតិដ្ឋឡើងនៅចំណុចផ្លូវប្រសព្វនានានៃរាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីរំដោះប្រជាពលរដ្ឋចេញពីការកកស្ទះដោយមានប្រសិទ្ធិភាព។ កាលពីថ្មីៗកន្លងទៅនេះ ការដ្ឋានសាងសង់ស្ពានអាកាសទី៥ នៅក្នុងរាជធានីភ្នំពេញបានបើកឲ្យប្រជាពលរដ្ឋធ្វើដំណើរសាកល្បងក្នុងអំឡុងពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិក្នុងគោលបំណងបញ្ចៀសនូវបញ្ហាកកស្ទះចរាចរណ៍ ស្របពេលដែលប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញកំពុងតែសម្រុកធ្វើដំណើរទៅស្រុកកំណើតរៀងៗខ្លួន។ យោងតាមទិន្នន័យរបស់សាលារាជធានីភ្នំពេញបច្ចុប្បន្ននេះ រាជធានីភ្នំពេញបច្ចុប្បន្ននេះមានស្ពានអាកាសចំនួន៥គឺ

- ស្ពានអាកាសក្បាលថ្នល់
- ស្ពានអាកាស ៧មករា
- ស្ពានអាកាសស្ទឹងមានជ័យ
- ស្ពានអាកាស ៥មករា
- ស្ពានអាកាសផ្សារដើមហុយ

### ២.២.៣ ការរៀបចំមធ្យោបាយធ្វើដំណើរសាធារណៈ

#### ២.២.៣.១ រថយន្តក្រុង

សេវាកម្មរថយន្តក្រុងសាធារណៈបាននឹងកំពុងតែដើរតួនាទីដល់សំខាន់ក្នុងការបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងជាកត្តាដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍។ រដ្ឋាភិបាលកម្ពុជាបានព្យាយាមធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដៃគូនានាក្នុងគោលបំណងពង្រីកវិសាលភាពនៃការប្រើប្រាស់មធ្យោបាយសាធារណៈឲ្យកាន់តែទូលំទូលាយ ជាពិសេសនោះគឺ ការកែផ្នត់គំនិតប្រជាពលរដ្ឋឲ្យពួកគាត់ងាកមកប្រើប្រាស់មធ្យោបាយសាធារណៈជំនួសឲ្យយានជំនិះឯកជនវិញ។

តម្រាយផ្លូវរត់របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញមានដូចខាងក្រោម៖

- ខ្សែរត់ទី១ ពីចំណតគីឡូម៉ែត្រលេខ៩ដល់ចំណតបឹងឈូក៖ ចេញពីចំណតគីឡូម៉ែតលេខ០៩ ដល់ចំណតបឹងឈូកដោយឆ្លងកាត់ផ្លូវជាតិលេខ០៥ រង្វង់មូលស្អាតចាស់មហាវិថីព្រះមុនីវង្ស ផ្សារច្បារអំពៅ កំណាត់ផ្លូវជាតិលេខ០១ ស្ថានីយ៍ចំណតបឹងឈូក។
- ខ្សែរត់ទី២ ពីចំណតផ្សារអ៊ីអន២ ដល់ក្រុងតាខ្មៅ៖ ចេញពីចំណតផ្សារអ៊ីអន២ តាមផ្លូវឧកញ្ញា

ម៉ុង រិទ្ធី ស្តុបកាំកូស៊ីធី អង់តែនទួលគោក ផ្លូវលេខ៧០ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ២ ដល់ក្រុងតាខ្មៅខេត្តកណ្តាល។

- ខ្សែរត់ទី៣ ពីសួនច្បារឫស្សីកែវ ដល់បុរីសន្តិភាព២ ៖ ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ស្ពានអាកាស៧មករា មហាវិធីសហព័ន្ធរុស្ស៊ី រង្វង់មូលចោមចៅផ្លូវជាតិលេខ៣ ដល់ចំណតបុរីសន្តិភាព២។
- ខ្សែរត់ទី៤A ពីចំណតសួនច្បារឫស្សីកែវ ដល់បុរីសន្តិភាព២ ៖ ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បួចកាណុង ផ្លូវជាតិលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាលឌឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីមុន្នីរ៉េតកាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវេងស្រេង ស្តុបអាងទឹក កាណាឌីយ៉ាផ្សារទួលពង្រ ដល់បុរីសន្តិភាព២។
- ខ្សែរត់ទី៤B ពីសួនច្បារឫស្សីកែវ ដល់ តំបន់សេដ្ឋកិច្ចពិសេស ៖ ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលគួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាលជឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុន្នីរ៉េតកាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវេងស្រេង រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៤ ដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។
- ខ្សែរត់ទី៥ ពីចំណតផ្សារអ៊ីអន២ ដល់ផ្សារអ៊ីអន១ ៖ ចេញពីចំណងផ្សារអ៊ីអន២ តាមផ្លូវលេខ១០០៣ បត់ឆ្វេងតាមផ្លូវលេខ១៩៦៦ឆ្ពោះទៅផ្លូវលេខ៦៩៨ ផ្លូវលេខ៣៣៧ បត់ស្តាំតាមផ្លូវលេខ៥៦៦ សាលាបឋមសិក្សាពៅអ៊ុំទួលគោក វិថីគីម អ៊ីលស៊ុង កាត់ក្រោមស្ពានអាកាសប្រាំមករា មហាវិថីម៉ៅសេទុង ស្តុបបូកគោ ស្តុបជលផល វិថីសុធារស ដល់ចំណតផ្សារអ៊ីអន១។
- ខ្សែរត់ទី៦ ពីចំណតផ្សារបុរីរុងរឿង ដល់ផ្សារសេនជូរីផ្លាហ្សា ៖ ចេញពីចំណតផ្សារបុរីរុងរឿងផ្លូវជាតិលេខ៦ ស្ពានជ្រោយចង្វារ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៧០ អង់តែនទួលគោក ស្តុបកាំកូស៊ីធី ផ្លូវឧកញ៉ា ម៉ុង រិទ្ធី ផ្លូវសម្តេច ជា ស៊ីម បត់ឆ្វេង ផ្លូវឧកញ៉ា ទ្រី ហេង ដល់មហាវិថីសហព័ន្ធរុស្ស៊ីបត់ឆ្វេង ឆ្ពោះទៅដល់ចំណតផ្សារសេនជូរីផ្លាហ្សា។
- ខ្សែរត់ទី៧ A ពីចំណតគីឡូម៉ែត្រលេខ០ ដល់ផ្សារអ៊ីអន១ ៖ ចេញពីចំណតគីឡូម៉ែតលេខ៩ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវកេ២៧១ បត់តាមវិថីទេពផន ផ្សារដេប៉ូកាត់ស្តុបនាងគង្ហីង ផ្សារអូរឫស្សី បត់ស្តាំតាមមហាវិថីព្រះមុនីវង្ស បត់ឆ្វេងតាមមហាវិថីព្រះ

សីហានុ មហាវិថីព្រះនរោត្តម បទ់ឆ្វេងតាមមហាវិធីឧកញ្ញាជ្រុនយូហាក់ វិថីព្រះសុធារស ដល់ចំណតផ្សារអ៊ីអន១។

- ខ្សែរត់ទី៧B ពីចំណតគីឡូម៉ែត្រលេខ៩ ដល់ផ្សារច្បារអំពៅះ ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវលេខ២៧១ កាត់ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវលេខ២៧១ ស្តុបក្បាលថ្នល់ ឆ្លងកាត់ស្ពានព្រះមុនីវង្សដល់ចំណតច្បារអំពៅ។
- ខ្សែរត់ទី៨ ពីចំណតគីឡូម៉ែត្រលេខ៩ ដល់ផ្សារបុរីរុងរឿង ៖ ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ស្ពានព្រែកព្នៅ ផ្លូវក្រវ៉ាត់ក្រុងទី៣ ផ្លូវជាតិលេខ៦ដល់ចំណតផ្សារបុរីរុងរឿង។
- ខ្សែរត់ទី៩ ពីចំណតបុរីសន្តិភាព២ ដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ៖ ចេញពីចំណតបុរីសន្តិភាព២ ផ្លូវជាតិលេខ៣ សួនឧស្សាហកម្មវឌ្ឍនៈ ផ្លូវប្រេទះឡាយ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រលប់មកបុរីសន្តិភាព២វិញ។

### ២.២.៣.២ រថភ្លើងអាកាស

ថ្វីត្បិតតែមិនទាន់បានលេចចេញជារូបរាងនៅឡើយ ប៉ុន្តែបច្ចុប្បន្ននេះក្រសួងសាធារណការ និងដឹកជញ្ជូនរួមជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន-កម្ពុជា ហៅកាត់ថា(JICA) កំពុងសិក្សាលើការសាងសងរថភ្លើងអាកាសគ្មានមនុស្សបើក(AGT)ចំនួន៩ខ្សែនៅរាជធានីភ្នំពេញ។ ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណៈការបានបញ្ជាក់ថា “ ការសិក្សាបឋមនេះ នឹងត្រូវបញ្ចប់នៅមុនឆ្នាំ២០១៨ និងចាប់ផ្តើមសាងសង់ជាផ្លូវការនៅឆ្នាំ២០១៩ និងបញ្ចប់មុនឆ្នាំ២០២៣ ដើម្បីជាការត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះក្នុងព្រឹត្តិការណ៍ស៊ីហ្គេមឆ្នាំ២០២៣ និងរំដោះបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញផងដែរ។ គម្រោងសាងសង់រថភ្លើងអាកាសបែបបច្ចេកវិទ្យាជប៉ុននេះមាន៩ខ្សែ សរុបប្រវែង១៨គីឡូម៉ែត្រ ដែលក្នុងនោះមានមហាវិថីហ្សាលដឺហ្គោល មហាវិថីមុនីរ៉េតផ្លូវវេងស្រេងឆ្ពោះទៅកាន់ព្រលានយន្តហោះ និងមួយខ្សែទៀតបែកខ្នែងទៅកាន់ផ្លូវជាតិលេខ៤ និងផ្លូវកប់ស្រូវឆ្ពោះទៅកាន់ពហុកីឡដ្ឋានជាតិថ្មីនៅព្រែកព្នៅ”[12]។

### ២.២.៣.៣ ស្ពានអាកាសថ្មើរជើង

ស្ពានអាកាសថ្មើរជើងគឺជាមធ្យោបាយថ្មីមួយដែលត្រូវបានគេលើកឡើងនៅដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ ចំពោះការវាយតម្លៃពីប្រជាពលរដ្ឋ ការសាងសង់ស្ពានអាកាសថ្មើរជើងត្រូវបានគេចាប់អារម្មណ៍ថា នឹងប្រាកដជាបានដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះនៅតាមចំណុចប្រសព្វនានា។ ឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ ស្ពានអាកាសថ្មើរជើងដំបូងបង្អស់នៅកម្ពុជាចំនួនពីរត្រូវបានប្រតិដ្ឋឡើងនៅតាមផ្លូវជាតិ

[12] www.opendevelopmentcambodia.net (ថតចម្លង នាថ្ងៃ ២៥ ខែមេសា ឆ្នាំ២០១៨)

លេខ៤ ត្រង់សាលាបឋមសិក្សាជម្ពូវ័ន្ត និងវិទ្យាល័យចំណេះទូទៅហ៊ុនសែនជម្ពូវ័ន្ត ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ ជាយរាជធានីភ្នំពេញដែលបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី០៥ ឧសភា ឆ្នាំ២០១៧ ។

ដោយឡែកបច្ចុប្បន្ននេះ ស្ពានអាកាសថ្មើរជើងនាងគង្ហីង ដែលជាស្ពានអាកាសថ្មើរជើងទីបីនៅក្នុងរាជធានីភ្នំពេញកំពុងតែស្ថាបនាហើយជិតនឹងរួចជាស្ថាពរនៅក្នុងពេលឆាប់ៗខាងមុននេះ ហើយចំពោះគម្រោងស្ពានអាកាសថ្មើរជើងនេះផងដែរ សាលារាជធានីបានឲ្យដឹងថា បើគម្រោងស្ថាបនាស្ពាននេះទទួលការគាំទ្រពីប្រជាពលរដ្ឋនោះ សាលារាជធានីភ្នំពេញអាចនឹងពង្រីកគម្រោងស្ថាបនានេះនៅលើផ្លូវផ្សេងៗមួយចំនួនទៀត ដែលស្ពានអាកាសថ្មើរជើងទាំងនេះនឹងត្រូវសាងសង់នៅមុខសាលារៀន មន្ទីរពេទ្យ និងផ្សារជាដើម ដើម្បីបង្កើនការការពារផ្នែកសុវត្ថិភាពជូនប្រជាពលរដ្ឋ នៅពេលឆ្លងកាត់ផ្លូវ និងកាត់បន្ថយការកកស្ទះចរាចរណ៍[13]។

### ២.២.៣.៤ ការដឹកជញ្ជូនតាមផ្លូវទឹក

នៅពេលដែលប្រជាពលរដ្ឋនិយាយអំពី "ហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន" ពួកគេទាំងអស់សុទ្ធតែបានលើកឡើងពីមធ្យោបាយដឹកជញ្ជូនតាម ផ្លូវល្បឿនលឿន ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែជាដើម ដែលជាទូទៅមិនសូវមានមនុស្សច្រើនទេដែលបានដឹងថាមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹកវាមានសក្តានុពលខ្លាំងក្នុងការលើកកម្ពស់ការប្រកួតប្រជែងលើផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា។ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសកម្មភាពតាមផ្លូវទឹក វានឹងត្រូវបានគេប្រើប្រាស់ដោយមានអត្ថប្រយោជន៍ក្នុងតម្លៃទាប ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម ទំនិញ ផលិតផលនាំចេញ និងធនធានផ្សេងទៀតពីខេត្តក្រុងនានាទៅកំពង់ផែភ្នំពេញ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាលើកទឹកចិត្តដល់សកម្មភាពដឹកជញ្ជូនបែបនេះវានឹងអាចកាត់បន្ថយការដឹកជញ្ជូនចរាចរណ៍ធ្ងន់ៗ ពីតាមបណ្តាខេត្តនានាមកកាន់រាជធានីភ្នំពេញ ។

បច្ចុប្បន្ននេះរដ្ឋាភិបាលកម្ពុជាកំពុងណែនាំសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់មកកាន់រាជធានីភ្នំពេញ។ ទោះបីប្រជាជនកម្ពុជាមានការនិយមខ្លាំងក្នុងការប្រើម៉ូតូឬរថយន្តផ្ទាល់ខ្លួនក៏ដោយ ប៉ុន្តែតាក់ស៊ីផ្លូវទឹកអាចទាក់ទាញចំណាប់អារម្មណ៍របស់ពួកគាត់ ហើយវាអាចផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគាត់ ជាពិសេសក្នុងចំណោមក្មេងៗជំនាន់ក្រោយ ក្នុងការគាំទ្រការដឹកជញ្ជូនសាធារណៈ។ កត្តានេះ មិនត្រឹមតែកាត់បន្ថយការដឹកជញ្ជូនតាមផ្លូវគោកនោះទេ ប៉ុន្តែការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកនឹងក្លាយជាដំណោះស្រាយជំនួសមួយដើម្បីកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានី។ គួរបញ្ជាក់ផងដែរថា រដ្ឋាភិបាលបានបើក

[13] www.postkhmer.com (ថតចម្លង នាថ្ងៃ១០ ខែកក្កដា ឆ្នាំ២០១៨)

ដំណើរការសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកនាមុនពេលចូលឆ្នាំខ្មែរឆ្នាំ ២០១៨ ដោយសេវាកម្មផ្លូវទឹកនេះ នឹងរត់ក្នុងចម្ងាយ ២៥ គីឡូម៉ែត្រក្នុងរយៈពេលប្រហែល ៣៥ នាទីជាមធ្យម។

យោងតាមក្រសួងសាធារណការនិងដឹកជញ្ជូនបានឱ្យដឹងថាទូកចំនួន២០គ្រឿងនឹងត្រូវបានប្រើប្រាស់ដើម្បីបម្រើដល់អ្នកដំណើរចំនួន៤ជើងជារៀងរាល់ថ្ងៃ។ ទូកនេះមានសមត្ថភាពអាចផ្ទុកអ្នកដំណើររហូតដល់ទៅ៩០នាក់ហើយបំពាក់ជាមួយនឹងម៉ាស៊ីនត្រជាក់និងប្រព័ន្ធសុវត្ថិភាព ព្រមទាំងអាចធ្វើដំណើរបាន៣០គីឡូម៉ែត្រក្នុងមួយម៉ោង។ ប្រសិនបើការធ្វើដំណើរតាមផ្លូវទឹកនេះបានដំណើរការ អ្នកធ្វើការទូទៅ និងកម្មកររោងចក្រមួយចំនួនដែលស្ថិតនៅមិនឆ្ងាយពីច្រាំងទន្លេនឹងអាចទាញយកប្រយោជន៍ពីសេវាកម្មនេះ។ នៅក្នុងដំណាក់កាលបន្ទាប់ ក្រសួងសាធារណការនិងដឹកជញ្ជូននឹងចាប់ផ្តើមការដឹកជញ្ជូនទំនិញ ដែលតភ្ជាប់ទៅកំពង់ផែរាជធានីភ្នំពេញសម្រាប់ការដឹកជញ្ជូនផលិតផលកសិកម្ម។ ការធ្វើដំណើរតាមទូកគឺមានល្បឿនលឿនជាងបីដងនៃការធ្វើដំណើរតាមផ្លូវគោកពីព្រោះគ្មានការកកស្ទះចរាចរណ៍នៅលើផ្លូវទឹកទេ ហើយការដឹកជញ្ជូនតាមផ្លូវទឹកនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍តាមដងផ្លូវពីបណ្តាខេត្តនានាមករាជធានីភ្នំពេញ ព្រមទាំងបានកាត់បន្ថយយានយន្តធុនធ្ងន់ដែលបណ្តាលឱ្យខូចខាតផ្លូវ និងគ្រោះថ្នាក់ចរាចរណ៍[14]។

### ២.២.៤. ការកាត់បន្ថយការប្រើប្រាស់យានយន្ត

បន្ទាប់ពីការអប់រំនិងផ្សព្វផ្សាយអំពីបញ្ហានានាពាក់ព័ន្ធនឹងការកកស្ទះចរាចរណ៍ ក្នុងនោះការកាត់បន្ថយការប្រើប្រាស់យានយន្តជាដំណោះស្រាយដ៏សំខាន់មួយដែលនឹងត្រូវបានលើកឡើងនៅក្នុងការអនុវត្តជាចាំបាច់របស់អាជ្ញាធរមានសមត្ថកិច្ចដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍។ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការណែនាំ និងផ្សព្វផ្សាយពីអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការប្រើប្រាស់យានយន្ត និងលាតត្រដាងអំពីផលអវិជ្ជមានចំពោះសង្គមទាំងមូលក្នុងករណីមានការកើនឡើងនៃការប្រើប្រាស់យានយន្តដល់ប្រជាពលរដ្ឋ ហើយលើសពីនេះទៅទៀតនោះចាំបាច់ត្រូវតែត្រួតពិនិត្យឲ្យបានល្អិតល្អន់បំផុតចំពោះការនាំចូលនូវប្រភេទយានជំនិះដែលមិនសាកសមសម្រាប់ការបើកបរនៅក្នុងប្រទេសកម្ពុជានិងត្រួតពិនិត្យចំពោះអ្នកបើកបរយានជំនិះដែលទាមទារឲ្យមានបណ្ណបើកបរត្រឹមត្រូវទៅតាមច្បាប់។ ឆ្លើយតបទៅនឹងបញ្ហានេះផងដែរ មួយរយៈចុងក្រោយនេះ គេឃើញមានការកើនឡើងចំនួនរថយន្តនៅក្នុងរាជធានីភ្នំពេញហើយតួយ៉ាងមានគ្រោះថ្នាក់ចរាចរណ៍មួយចំនួនបានបង្កឡើងដោយជនបរទេសដែលច្បាប់មិនបានប្រគល់សិទ្ធិឲ្យបើកបរនៅក្នុងប្រទេសកម្ពុជា។ ការកាត់បន្ថយចំនួនយានយន្តនៅកម្ពុជាមិនត្រឹមតែធានាឲ្យការកាត់បន្ថយការកកស្ទះចរាចរណ៍

[14] www.urbanvoicecambodia.com (ថតចម្លងនាថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨)

នៅក្នុងរាជធានីភ្នំពេញមានប្រសិទ្ធិភាពប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងជួយសម្រាលបញ្ហាសណ្តាប់ធ្នាប់សាធារណៈនិងចៀសវាងការបំពុលបរិស្ថានផងដែរ។

### ២.២.៥ ការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព និងទំនួលខុសត្រូវ

គ្រប់ការអនុវត្តវិធានការ ឬផែនការរបស់អង្គភាពសាធារណៈ ចាំបាច់ទាមទារឲ្យការអនុវត្តនោះ ទទួលបានភាពជោគជ័យត្រលប់មកវិញ ហើយដើម្បីទទួលបាននូវលទ្ធផលល្អ មន្ត្រីសាធារណៈដែលទទួលបន្ទុកកិច្ចការទាំងនោះ ចាំបាច់ត្រូវតែបំពេញការងារដោយម៉ត់ចត់ យកចិត្តទុកដាក់ អត់ធ្មត់ និងមានផែនការអនុវត្តសកម្មភាពត្រឹមត្រូវច្បាស់លាស់។ ជាក់ស្តែងណាស់ នៅក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នេះ សាលារាជធានីភ្នំពេញបានដាក់ចេញនូវយុទ្ធនាការមួយ ដែលប្រជាពលរដ្ឋស្ទើរតែគ្រប់គ្នាបានដឹងថា ជាយុទ្ធនាការរំដោះចិញ្ចើមផ្លូវ ពីការរំលោភបំពានរបស់អ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវ។ ប៉ុន្តែចំពោះលទ្ធផលនៃការអនុវត្តយុទ្ធនាការរំដោះចិញ្ចើមផ្លូវវិញនោះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានលើកឡើងក្នុងពេលចូលរួមបិទសន្និបាតបូកសរុបការងាររបស់សាលារាជធានីភ្នំពេញ នារសៀលថ្ងៃទី៧ ខែកុម្ភៈ ថា " ការដែលកាសែនភ្នំពេញប៉ុស្តិ៍ថា សាលារាជធានីភ្នំពេញបរាជ័យក្នុងយុទ្ធនាការរំដោះចិញ្ចើមផ្លូវនោះ ហាក់បីដូចជាត្រឹមត្រូវ ហើយសំខាន់យើងមិនទាន់អាចដោះស្រាយបញ្ហាហ្នឹងបានមែន ហើយគេថាហ្នឹងត្រឹមត្រូវរបស់គេហើយ ព្រោះពលរដ្ឋយើងគាត់លក់ដូរស្ទើរតែគ្រប់កន្លែង។ បើពលរដ្ឋយើងយល់ដឹងពីសណ្តាប់ធ្នាប់នេះច្រើនរាជធានីរបស់យើងនឹងកាន់តែមានសម្រស់ថែមទៀត[15]"។

លើសពីនេះទៅទៀតនោះ អ្វីដែលថ្នាក់ដឹកនាំ និងមន្ត្រីរាជការគួរតែយកចិត្តទុកដាក់នោះគឺការអនុវត្តការបើកបរជាគំរូសម្រាប់ប្រជាពលរដ្ឋមើលឃើញអំពីគុណតម្លៃដ៏គួរឲ្យគោរពរបស់អ្នកដឹកនាំប្រទេស។ សម័យកាលនេះទៅហើយ បើទោះបីជាបច្ចេកវិទ្យាក្នុងប្រទេសយើងមិនអាចប្រៀបផ្ទឹមនឹងប្រទេសអភិវឌ្ឍធំៗបានក៏ដោយប៉ុន្តែប្រសិនបើទង្វើរបស់បុគ្គលណាម្នាក់ធ្វើឲ្យមានផលប៉ះពាល់ដ៏សង្គមនោះ អ្នកប្រើប្រាស់ក្នុងប្រព័ន្ធសង្គមអ៊ីនធឺណេតនានាប្រាកដជាចេញមុនវាយប្រហារ ហើយនឹងមានប្រជាពលរដ្ឋរាប់ម៉ឺននាក់បាននឹងកំពុងមើលផងដែរ។ ទស្សនៈជាច្រើនលើកឡើងថា បើគេថតបាន ឬឃើញប្រជាពលរដ្ឋណាម្នាក់ជាអ្នកបើកបរបញ្ច្រាសផ្លូវ គេចាត់ទុកថាមកពីគាត់មិនបានយល់ពីច្បាប់ មិនយល់ពីការបើកបរ ឬជាមនុស្សអាត្មានិយម ចុះប្រសិនបើមន្ត្រីរាជការម្នាក់ដែលកំពុងនឹងប្រើប្រាស់មធ្យោបាយសាធារណៈហើយបានបំពានដូចគ្នានោះ តើប្រជាពលរដ្ឋមានការយល់យ៉ាងដូចម្តេច?

---

[15] www.postkhmer.com (ថតចម្លង នាថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៨)

**២.២.៦ ការចូលរួមរបស់ប្រជាពលរដ្ឋ**

ការចូលរួមរបស់ប្រជាពលរដ្ឋពិតជាមានសារៈសំខាន់ ចំពោះការដោះស្រាយបញ្ហានានារបស់រដ្ឋ ពីព្រោះថាពេលខ្លះប្រជាពលរដ្ឋអាចជាអ្នកជួបប្រទះបញ្ហាអស់ទាំងនោះដោយផ្ទាល់ ដូច្នេះការចូលរួមរបស់ពួកគាត់ពិតជាមានអត្ថប្រយោជន៍ខ្លាំង។ ជាក់ស្តែងចំពោះបញ្ហាកកស្ទះនេះ បើប្រជាពលរដ្ឋនីមួយៗចេះយោគយល់អធ្យាស្រ័យគ្នាក្នុងនាមជាអ្នកបើកបរដូចគ្នានោះ ម្លេះសមនឹងបញ្ហានេះត្រូវបានកាត់បន្ថយជាអតិបរិមាជាក់ជាមិនខាន។ ចូរផ្តើមធ្វើជាពលរដ្ឋគំរូនៅក្នុងសង្គមរស់នៅដើម្បីកែលម្អអ្វីដែលជាចំណុចអវិជ្ជមាននៅក្នុងសង្គម យូរទៅៗប្រជាពលរដ្ឋផ្សេងៗទៀតនឹងចាប់ផ្តើមអនុវត្តរហូតក្លាយទៅជាសង្គមដែលពោលពេញដោយភាពល្អប្រសើរ និងសេចក្តីថ្លៃថ្នូរ។

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ប្រជាពលរដ្ឋគួរតែត្រូវបានយល់ដឹងពីអ្វីដែលមានចែងនៅក្នុងច្បាប់ចរាចរណ៍ ហើយកត្តាសំខាន់ទាក់ទងនឹងចរាចរណ៍នោះគឺសិទ្ធិអាទិភាព ដោយយោងតាមច្បាប់ចរាចរណ៍ផ្លូវគោក ត្រង់មាត្រា២១ បានចែងថា សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ត្រូវបានកំណត់ដូចខាងក្រោម៖

១.គ្រប់អ្នកបើកបរនៅពេលដែលទៅជិតដល់ផ្លូវប្រសព្វ ត្រូវបន្ថយល្បឿននិងពិនិត្យមើលចលនាចរាចរណ៍នៅលើទ្រូងផ្លូវដែលខ្លួនត្រូវឆ្លងកាត់នោះ ហើយត្រូវធ្វើដំណើរឆ្លងកាត់ដោយប្រុងប្រយ័ត្នបំផុត បើផ្លូវខាងមុខមិនស្រលះល្អ។ ក្នុងករណីចាំបាច់ ត្រូវធ្វើសញ្ញាឲ្យដំណឹងដល់អ្នកបើកបរដែលមកពីផ្លូវផ្សេងគ្នា ដោយប្រើសញ្ញាសូរសព្ទពេលថ្ងៃ និងប្រើភ្លើងសញ្ញាភ្លឹបភ្លែតនៅពេលយប់។ នៅលើផ្លូវផ្តល់សិទ្ធិអាទិភាពឲ្យគេ អ្នកបើកបរត្រូវបើកបរក្នុងល្បឿនមួយដែលអាចបញ្ឈប់យានខ្លួនបានដើម្បីផ្តល់សិទ្ធិដល់យានដែលនៅលើផ្លូវមានសិទ្ធិទៅមុន។

២.ទោះបីនៅត្រង់ផ្លូវប្រសព្វមានភ្លើងសញ្ញាចរាចរណ៍ពណ៌បៃតងដែលអនុញ្ញាតឲ្យធ្វើចរាចរណ៍ទៅមុខបានក៏ដោយ ក៏អ្នកបើកបរមិនត្រូវបើកចូលទៅក្នុងផ្លូវប្រសព្វឡើយ ប្រសិនបើអំពើនេះអាចតម្រូវឲ្យខ្លួនបញ្ឈប់យានជំនិះនៅក្នុងផ្លូវប្រសព្វដោយសារតែមានចរាចរណ៍ចង្អៀតខ្លាំង។ ក្នុងករណីបែបនេះ អ្នកបើកបរត្រូវឈប់នៅមុខផ្លូវប្រសព្វ ដើម្បីកុំឲ្យស្ទះចរាចរណ៍យានដែលមកពីទិសផ្សេងទៀត។

៣. នៅផ្លូវប្រសព្វដែលគ្មានសញ្ញាអាទិភាព អ្នកបើកបរត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយានដែលមកពីស្តាំរបស់ខ្លួនទៅមុន។ ប៉ុន្តែក្នុងករណីផ្លូវប្រសព្វបែកជាបីដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរយាននៅផ្លូវដែលចប់ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយាននៅផ្លូវត្រូវបន្តទៅមុខ។

៤. អ្នកបើកបរដែលទៅដល់រង្វង់មូល ទោះបីខ្លួនស្ថិតនៅក្នុងផ្លូវប្រភេទណាក៏ដោយ ត្រូវផ្តល់សិទ្ធិអាទិភាពឲ្យអ្នកបើកបរដែលស្ថិតនៅក្នុងទ្រូងផ្លូវឯកទិសក្រវាត់រង្វង់មូលដែលមានសញ្ញាបង្ហាញ

ទិសទៅមុន។

៥. នៅពេលទៅដល់ផ្លូវប្រសព្វដែលមានសញ្ញាសម្គាល់សិទ្ធិអាទិភាព អ្នកបើកបរត្រូវទុកផ្លូវឲ្យយានជំនិះដែលស្ថិតនៅលើផ្លូវមានសិទ្ធិអាទិភាពធ្វើដំណើរទៅមុនហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបានតែនៅពេលណាដែលខ្លួនជឿងជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៦. នៅពេលទៅដល់ផ្លូវប្រសព្វដែលមានដាក់សញ្ញាថា ឈប់ អ្នកបើកបរត្រូវឈប់ស្ងៀមនៅមុខគំនូសកាត់ទទឹងទ្រូងផ្លូវ ដើម្បីទុកឲ្យយានជំនិះនិងថ្មើរជើងដែលនៅលើផ្លូវមានសិទ្ធិធ្វើដំណើរទៅមុខ ហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបានតែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៧. ដោយឡែកអ្នកបើកបរត្រូវតែទុកឲ្យយានជំនិះបម្រើការរបស់នគរបាល យោធា កងរាជអាវុធហត្ថ យានពន្លត់អគ្គិភ័យ ឬយានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ចដោយឲ្យសញ្ញាសូរសព្ទ និងសញ្ញាភ្លើងពិសេសឲ្យដឹងអំពីការមកដល់របស់ខ្លួនទៅមុន។

៨.យានជំនិះកំពុងបំពេញភារកិច្ចដូចខាងក្រោមមានសិទ្ធិអាទិភាពតាមលំដាប់ដូចតទៅៈ

- យានពន្លត់អគ្គិភ័យ
- យានសង្គ្រោះរបស់មន្ទីរពេទ្យ
- យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ

៩.មុននឹងបើកបរចេញពីផ្លូវឯកជនដែលមិនបើកឲ្យធ្វើចរាចរណ៍ជាសាធារណៈដូចជា ពីច្រកគេហដ្ឋាន រោងចក្រ អគារ ឬទីលានផ្សេងៗ អ្នកបើកបរត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវទុកសិទ្ធិអាទិភាពឲ្យយានជំនិះ ឬថ្មើរជើងដែលកំពុងចរាចរណ៍លើផ្លូវសាធារណៈទៅមុន។

១០. អ្នកបើកបរចេញពីផ្លូវលំ ឬផ្លូវដី ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរលើផ្លូវផ្សេងទៀតដែលមិនមែនជាផ្លូវលំ ឬផ្លូវដើរទៅមុន។

១១. នៅត្រង់ផ្លូវប្រសព្វ បើទ្រូងផ្លូវមួយមានចែកជាច្រើនគន្លងផ្លូវ ហើយមានគន្លងផ្លូវមួយឬច្រើនត្រូវបម្រុងសម្រាប់យានជំនិះប្រភេទខ្លះធ្វើចរាចរណ៍ បទប្បញ្ញត្តិស្តីពីអាទិភាពចរាចរណ៍ដែលមានចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះអ្នកបើកបរដែលធ្វើចរាចរណ៍លើគន្លងផ្លូវប្រភេទនេះ លើកលែងតែយានជំនិះដែលមានចែងនៅក្នុងចំណុចទី៧ និងចំណុចទី៨ខាងលើនេះ។

ក្រៅពីនេះប្រជាពលរដ្ឋត្រូវធ្វើការស្វែងយល់អំពីអត្ថន័យនៃខ្លឹមសារមួយចំនួនទៀត ដែលជាទូទៅតែងតែមានការភ័ន្តច្រឡំពាក់ព័ន្ធនឹងពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងផ្លូវថ្នល់ ជៀសវាងការរំលោភបំពានលើច្បាប់ស្តីពីផ្លូវថ្នល់ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកៈ

- ទ្រូងផ្លូវ សំដៅដល់ចំណែកនៃផ្លូវទុកសម្រាប់ឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។
- ជាយផ្លូវ សំដៅលើផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជន ដែលយានជំនិះអាចចតនៅទីនោះបានក្នុងករណីចាំបាច់។
- ចិញ្ចើមផ្លូវ សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។
- គន្លងផ្លូវ សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ខណ្ឌដោយគំនូស ឬបរិក្ខារចែងចំណែកផ្លូវតាមបណ្ដោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។
- ច្រកចេញចូលផ្ទះឯកជន សំដៅដល់ច្រកចេញចូលផ្ទះដែលមានផ្ទៃរាបស្មើភ្ជាប់ជាមួយនឹងផ្លូវសាធារណៈ និងមិនមែនជាចិញ្ចើមផ្លូវ។
- ឈប់ សំដៅលើការនៅស្ងៀមរបស់យានជំនិះលើទ្រូងផ្លូវមួយរយៈពេលខ្លី ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះរបស់ខ្លួន ដើម្បីឲ្យអ្នកធ្វើដំណើរ ឬយានជំនិះដទៃឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ
- ចត សំដៅដល់ការទុកឲ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរ ឬឆាប់ ដែលអ្នកបើកបរអាចដើរចោលយានជំនិះរបស់ខ្លួនបាន។

ក្រៅពីនេះទៅទៀតនោះ ក្នុងនាមជាប្រជាពលរដ្ឋនៃរដ្ឋមួយ ក្នុងនាមជាម្ចាស់នៃប្រទេសមួយចាំបាច់មានភារកិច្ចក្នុងការចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ស្រទាប់ជាន់ថ្នាក់ក្នុងការអនុវត្តច្បាប់ក្នុងប្រទេសឲ្យមានប្រសិទ្ធិភាព នឹងចៀងវាងឲ្យបានរាល់ទង្វើទាំងឡាយណាដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គមទាំងមូល ជាពិសេសការផ្សព្វផ្សាយព័ត៌មានទាំងឡាយគ្មានប្រភពដំណឹងច្បាស់លាស់ដែលទង្វើទាំងអស់នោះមិនត្រឹមតែមិនបានចូលរួមកែលម្អសង្គមនោះទេ ថែមទាំងបង្កជាបញ្ហាដល់សណ្ដាប់ធ្នាប់សាធារណៈថែមទៀតផង។

*ការចូលរួមកសាងសង្គម ជាអ្វីដែលប្រជាពលរដ្ឋកម្ពុជាត្រូវបំពេញក្នុងពេលបច្ចុប្បន្ននេះ!*

## ២.៣ វិធានការអនុវត្តចំពោះបញ្ហាកកស្ទះចរាចរណ៍

### ២.៣.១. ការណែនាំ និងចាត់វិធានការចំពោះបញ្ហាសណ្ដាប់ធ្នាប់តាមដងផ្លូវ

បញ្ហានៅក្នុងសង្គមមួយអាចនឹងត្រូវដោះស្រាយបាន អាស្រ័យដោយសារការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកដែលពាក់ព័ន្ធនានានៅក្នុងបញ្ហានោះ ហើយក្នុងករណីដែលភាគីទាំងឡាយមិនបានសហការណ៍ទេនោះ រដ្ឋនឹងចាត់វិធានការទៅតាមផ្លូវច្បាប់។ ចំពោះបញ្ហាដែលបងប្អូនអាជីវករជាច្រើនបានរំលោភលើចំណីផ្លូវដើម្បីដំណើរការមុខរបរជួញដូររបស់ខ្លួននោះ ប្រហែលជាដល់

ពេលដែលអាជ្ញាធរត្រូវអនុវត្តវិធានការច្បាប់ ដាក់ទណ្ឌកម្មចំពោះអ្នកដែលល្មើសនោះហើយ។ ជាការអនុវត្តគំរូមួយ " ស្លាកយីហោលក់ទូរស័ព្ទ ដែលរំលោភលើចិញ្ចើមផ្លូវ និងបង្កគ្រោះថ្នាក់ដល់អ្នកដំណើរ ដែលនៅតែរឹងរូសមិនស្តាប់តាមការណែនាំ ត្រូវបានអាជ្ញាធរចុះទៅកាត់ទម្លាក់ចោល កាលពីវេលាម៉ោង ប្រមាណ៤ល្ងាចថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៨នេះ។ ស្លាកដែលបង្កគ្រោះថ្នាក់ជាស្លាកលក់ទូរសព្ទដៃយីហោ មេត្តាស្មានហ្វូន ស្ថិតនៅផ្ទះលេខ២១១B ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក។ ស្លាកលក់ទូរស័ព្ទដៃនេះបានដាក់លើចិញ្ចើមផ្លូវ និងមានកម្ពស់ប្រមាណ១ម៉ែត្រ ជាហេតុបង្កគ្រោះថ្នាក់ដល់អ្នកដំណើរ។ កន្លងមកស្លាកនេះបង្កគ្រោះថ្នាក់ដល់ស្ត្រីម្នាក់បណ្តាលឲ្យរយះក្បាលម្តងមកហើយ បន្ទាប់ពីមានមនុស្សគ្រោះថ្នាក់អាជ្ញាធរ ក៏បានចុះទៅណែនាំឲ្យម្ចាស់រុះរើ តែម្ចាស់ពុំព្រមផ្តិតមេដៃសហការ និងពុំព្រមរុះរើទើបអាជ្ញាធរសង្កាត់រាយការណ៍ទៅសាលាខណ្ឌ ចុះមកកាត់យកទៅទុកសាលាខណ្ឌ។ តាមព័ត៌មានឲ្យដឹងទៀតថា នៅពេលដែលអាជ្ញាធរ ចុះទៅកាត់ស្លាកនេះមានការប្រទូស្តគ្នាដោយលោក ទារ សំអឿន ក៏បានស្ទុះទៅចាប់យកទូរសព្ទរបស់ម្ចាស់ហាង ដែលបានថតរូបសមត្ថកិច្ចដែលបានចុះទៅកាត់ស្លាកនោះ" [16]។

ចំពោះដំណោះស្រាយបញ្ហាទាំងអស់នេះផងដែរ យោងតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញបានសម្រេចជ្រើសរើសយកផ្លូវសំខាន់ៗចំនួន១១ខ្សែ ធ្វើជាអាទិភាពគំរូសម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ ហើយផ្លូវគំរូអាទិភាពទាំងនោះរួមមាន៖ មហាវិថីសហព័ន្ធរុស្ស៊ី មហាវិថីព្រះមុនីវង្ស មហាវិថីកម្ពុជាក្រោម មហាវិថីម៉ៅសេទុង មហាវិថីព្រះសីហនុ និងមហាវិថីនេរូហ៍ មហាវិថីព្រះនរោត្តម មហាវិថីសម្តេចមុនីរ៉េត ផ្លូវឧកញ៉ាទេពផន មហាវិថីហ្សាលដឺហ្គោល មហាវិថីយោធពលខេមរភូមិន្ទ(ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង(ផ្លូវលេខ៧០) និងតីរវិថីព្រះស៊ីសុវត្ថិ។ ដើម្បីសម្រេចបានផែនការកាត់បន្ថយការកកស្ទះចរាចរណ៍នោះ រដ្ឋបាលរាជធានីភ្នំពេញបានដាក់ចេញសេចក្តីណែនាំដូចខាងក្រោម៖

ក. ចំពោះប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្ម ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀនវិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្ទាល់ត្រូវអនុវត្ត៖

- ហាមចតយានយន្តគ្រប់ប្រភេទលើទ្រូងផ្លូវ ហាមដាច់ខាតមិនឲ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣(មួយភាគបី) និងឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារសំណង់របស់ខ្លួនដូចជា ដែក ខ្សាច់ គ្រួស ថ្មជាដើម។

[16] https://kohsantepheapdaily.com.kh/article/590763.html (ថតចម្លង នាថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៨)

- រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញចូលគោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុង ចាប់ពីម៉ោង២១:០០នាទី រហូតដល់ម៉ោង០៦:០០នាទីព្រឹក។
- ការរៀបចំសម្ភារ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម១/៣(មួយភាគបី) ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើការងារសណ្តាប់ធ្នាប់និងចរាចរណ៍។
- រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនឲ្យលើសពី១/៣(មួយភាគបី)ឡើយ។

ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ត្រូវអនុវត្តដូចខាងក្រោម៖

- ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់តែម៉ឺងម៉ាត់ ឲ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្តីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនោះទេ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។
- ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឲ្យគោរពតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅដល់ការបិទទីតាំងអាជីវកម្ម។
- ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឲ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានលើទ្រូងផ្លូវ ចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាលត្រូវផ្អាកការដ្ឋាននោះភ្លាម
- ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង រថយន្តក្រឡុកស៊ីម៉ងត៍ និងត្រូវមានវិធានការឲ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញចូលរាជធានីភ្នំពេញខុសពីសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។
- ត្រូវអនុវត្តតាមការណែនាំខាងលើនេះឲ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្តាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឲ្យបានទៀងទាត់ និងទាន់ពេលវេលា។

គ. ស្នងការដ្ឋាននគរបាល និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖

- បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយចរាចរណ៍តាមគោលដៅដែលមានការកកស្ទះនៅចន្លោះម៉ោងមមាញឹកគឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨ : ៣០នាទី ម៉ោង ១១ : ៣០នាទីដល់ម៉ោង ១២ :៣០ នាទី និងម៉ោង១៧ : ០០ ដល់ម៉ោង ១៨ : ៣០ នាទី។
- រៀបចំរថយន្តស្ទូច ក្នុងគោលបំណងសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។

### ២.៣.២ ការប្រើប្រាស់កម្លាំងជាក់ស្តែង

បច្ចុប្បន្ននេះ ស្នងការដ្ឋាននគរបាលរាជធានីបាននឹងកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសម្រួលចរាចរណ៍នៅតាមគោលដៅនីមួយៗក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងធានាទាំងការបម្រើសុវត្ថិភាពជូនប្រជាពលរដ្ឋ និងការរៀបចំសណ្តាប់ធ្នាប់។ ចំពោះបញ្ហារៀបចំសណ្តាប់ធ្នាប់ និងដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នេះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានប្រើប្រាស់កម្លាំងសរុបចំនួន ១.០៩១នាក់/១៨៥គោលដៅ(ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក៥៩០/៧០គោលដៅ) ការិយាល័យនគរបាលសណ្តាប់ធ្នាប់ចំនួន៤២នាក់/០៦គោលដៅ អង្គភាពអន្តរាគមន៍ពិសេសចំនួន៦០នាក់ តាមបណ្តាខណ្ឌទាំង១២ចំនួន៣៩៩នាក់/១០៩គោលដៅ ក្នុងនោះរួមមានៈ

- ការិយាល័យន.បចរាចរណ៍ផ្លូវគោក ៤៩៦នាក់/៦២គោលដៅ (បញ្ជាការ ១៦នាក់)
- អធិការដ្ឋានន.បខណ្ឌដូនពេញ ២៥នាក់/០៨គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌ៧មករា ៥៨នាក់/២២គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌចំការមន ៦៣នាក់/១៥គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌទួលគោក ៦៣នាក់/២០គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌឫស្សីកែវ ១៩នាក់/០៧គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌជ្រោយចង្វារ ១៥នាក់/០៣គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌព្រែកព្នៅ ១៤នាក់/០២គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌសែនសុខ ៣០នាក់/១០គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌពោធិ៍សែនជ័យ ៣៣នាក់/០៦គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌដង្កោ ២៧នាក់/០៦គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌមានជ័យ ២៦នាក់/០៥គោលដៅ (បញ្ជាការ ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌច្បារអំពៅ ២៦នាក់/០៥គោលដៅ (បញ្ជាការ ០៣នាក់)

នៅក្នុងចំណោមចំណុចកកស្ទះទាំង២០ផ្សារ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានប្រើប្រាស់កម្លាំងការិយាល័យនគរបាលសណ្តាប់ធ្នាប់ចំនួន ២៩នាក់/០៤ផ្សារ(ផ្សារធំថ្មី ផ្សារអូឫស្សី

ផ្សារអូរឡាំពិក ផ្សារដើមគរ) និងចំនួន១៦ផ្សារទៀតប្រើប្រាស់កម្លាំងរដ្ឋបាលខណ្ឌ។

ចំពោះល្បាតចល័តរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានប្រើប្រាស់កម្លាំង ២៧នាក់(បញ្ជាការ០៣នាក់) /០៩គោលដៅសំខាន់ឲ្យធ្វើការល្បាតចល័តរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈនៅតាមមហាវិថីសំខាន់ៗ និងចំណុចស្មុគស្មាញកកស្ទះចរាចរណ៍(ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក កម្លាំង១៤នាក់/ រថយន្តស្ទូច ០៧គ្រឿង/០៧គោលដៅ ការិយាល័យនគរបាលសណ្តាប់ធ្នាប់ កម្លាំង១៣នាក់/ រថយន្តស្ទូច ០២គ្រឿង/ ០២គោលដៅ) ។

ចំពោះកម្លាំងអន្តរាគមន៍វិញនោះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ប្រើប្រាស់កម្លាំងចំនួន ១៤០នាក់(រថយន្ត១០គ្រឿង) ក្នុងនោះមាន កងអន្តរាគមន៍នៃការិយាល័យកណ្តាលសណ្តាប់ធ្នាប់ចំនួន ៨០នាក់(ចែកជា៣ខ និង៣ក្រុម) និងអង្គភាពអន្តរាគមន៍ពិសេសចំនួន៦០នាក់។ កម្លាំងអន្តរាគមន៍ទាំងពីរក្រុមនេះ ត្រូវទទួលភារកិច្ចត្រៀមអន្តរាគមន៍នៅកន្លែងដែលមានការកកស្ទះចរាចរណ៍ធ្ងន់ធ្ងរ ឬពេលមានព្រឹត្តិការណ៍ការពារសំខាន់ៗ។

### ២.៣.៣ អំពីភារកិច្ចរបស់នគរបាលចរាចរណ៍

ដើម្បីធានាការដោះស្រាយបញ្ហាចរាចរណ៍ក្នុងរាជធានីភ្នំពេញ មន្ត្រីនគរបាលចរាចរណ៍ដែលស្ថិតនៅតាមគោលដៅនីមួយៗ ចាំបាច់ត្រូវមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តភារកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក(ជំពូកទី០៩ មាត្រា៦០ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក)។
- ក្តាប់សភាពការណ៍ និងព្យាករណ៍រាល់ការកកស្ទះ ដោយធ្វើការសិក្សាលក្ខណៈភូមិសាស្ត្រជាក់ស្តែងនូវចំណុចកកស្ទះ រៀបចំដំឡើងផែនទី និងការប្រើប្រាស់កម្លាំងជំនាញអនុវត្តឲ្យបានសមស្របទាន់ពេលវេលា(មិនទុកឲ្យមានការកកស្ទះណែនណាប់ ទើបធ្វើការដោះស្រាយជាក្រោយ)។
- រៀបចំសណ្តាប់ធ្នាប់សាធារណលើទ្រូងផ្លូវ-ចិញ្ចើមផ្លូវ ជុំវិញទីផ្សារធំៗ (ការតាំងលក់ដូរ ធ្វើអាជីវកម្ម ការឈប់-ចតយានយន្ត ចំណតគ្មានសណ្តាប់ធ្នាប់លើផ្លូវ) ចំណតរថយន្តឈ្នួល-តាក់ស៊ី អាជីវកម្មដ្ឋាន(ភោជនីយដ្ឋាន សណ្ឋាគារ រង្គសាល...) ក្រសួង មន្ទីរ ក្រុមហ៊ុន គ្រឹះស្ថានសិក្សានានា ដោយសហការជាមួយស្ថាប័ន អាជ្ញាធរដែនដី និងកម្លាំងពាក់ព័ន្ធ។
- បំប៉នសមត្ថភាពជំនាញ និងច្បាប់ដល់មន្ត្រីនគរបាលអនុវត្តផ្ទាល់ ហ្វឹកហាត់របៀបរហួនគោរពបានវិន័យអាកប្បកិរិយា សីលធម៌ស្មោះត្រង់ ទន់ភ្លន់ ម៉ឺងម៉ាត់ ស្មារតីទទួលខុសត្រូវ។
- កសាងផែនការជាក់ស្តែងតាមការិយាល័យជំនាញ និងអធិការដ្ឋាននគរបាលខណ្ឌនីមួយៗ

(មានផែនទីភូមិសាស្ត្រ) និងផ្សព្វផ្សាយដល់កងកម្លាំងអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់។

- អនុវត្តផែនការលេខ ០០២ ផ.ក ចុះថ្ងៃ០១ មករា ឆ្នាំ២០១៦ របស់ស្នងការដ្ឋានរាជធានីភ្នំពេញ ស្តីពីការរក្សាសណ្តាប់ធ្នាប់នៃការធ្វើចរាចរណ៍រថយន្តដឹកជញ្ជូនគ្រប់ប្រភេទចេញ-ចូលរាជធានីភ្នំពេញ។
- ធ្វើរបាយការណ៍បូកសរុបជាប្រចាំថ្ងៃ-សប្តាហ៍ និងខែ ផ្ញើមកស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីបូកសរុបដកពិសោធន៍រាយការណ៍ ជូនរដ្ឋបាលរាជធានីភ្នំពេញ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។

គួរបញ្ជាក់ផងដែរថា នៅប្រតិបត្តិការនីមួយៗ អគ្គស្នងការនគរបាលរាជធានីភ្នំពេញបាននឹងកំពុងប្រើប្រាស់មធ្យោបាយប្រតិបត្តិការជារួមមាន រថយន្តចំនួន៣៧គ្រឿង (រថយន្តស្វូចចំនួន០៩គ្រឿង រថយន្តដឹកកងកម្លាំងចំនួន២៨គ្រឿង) និងម៉ូតូធំចំនួន ១៩០គ្រឿង។

កាលពីខែមីនាថ្មីនេះ បន្ទាប់ពីបញ្ហាចរាចរណ៍បានកើតឡើងនិងការតែរីករាលដាលបង្កជាការលំបាកយ៉ាងខ្លាំងនោះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានដាក់វិធានការជាបន្តបន្ទាប់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពដូចខាងក្រោម៖

- បង្កើនជំរុញការផ្សព្វផ្សាយ អប់រំ ណែនាំអំពីច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានទូលំទូលាយពីរាជធានីដល់ខណ្ឌ សង្កាត់ ភូមិ សហគមន៍ តាមគ្រប់រូបភាពនិងគ្រប់ប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី បណ្តាញទំនាក់ទំនងសង្គម...)។
- បន្តនិរន្តភាពនៃការអនុវត្តច្បាប់ ដោយបង្កើនក្រុមត្រួតពិនិត្យ និងយកចិត្តទុកដាក់លើបទល្មើសចរាចរណ៍អំពីការបើកបរលើសល្បឿនកំណត់ បើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ការត្រួតពិនិត្យលិខិតស្នាមយានយន្ត និងអ្នកបើកបរ។ល។ ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ០០៩សណន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ របស់ស្នងការដ្ឋាននគរបាលជាតិ ស្តីពីការបន្តត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពស្តីពីការត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកនៅរាជធានីភ្នំពេញ របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ(ផែនការលេខ០៩៩ផកចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦)។ អនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តនាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ និងស្មារតីអង្គប្រជុំនៅអគ្គស្នងការដ្ឋាននគរបាលជាតិនាថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលវិធានការរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរៀបចំផែនការស្តីពីការកែសម្រួលគោលដៅត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នៅរាជធានីភ្នំពេញ។

- បង្កើនប្រសិទ្ធិភាពក្រុមការងារចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តតាមគោលដៅក្នុងរាជធានីភ្នំពេញ (តាមលិខិតបង្គាប់ការលេខ០០១/១៧ លបក.រ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០១៧ របស់រដ្ឋបាលរាជធានីភ្នំពេញ)
- បូកសរុបស្រង់ស្ថិតិអ្នកបើកបរ និងម្ចាស់យានយន្តមិនព្រមចូលខ្លួនបង់ផាកពិន័យត្រៀមលក្ខណៈកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ( ករណីមិនចូលខ្លួនមកបង់ផាកពិន័យលើសពី៩០ថ្ងៃ) និងចេញលិខិតអញ្ជើញក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋឲ្យចូលមកបង់ប្រាក់ផាកពិន័យ។
- ពង្រឹងប្រសិទ្ធិភាពការអនុវត្តសេចក្ដីណែនាំលេខ១៩ សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ របស់សាលារាជធានីភ្នំពេញស្ដីពីសណ្ដាប់ធ្នាប់នៃការធ្វើចរាចរណ៍រថយន្តដឹកជញ្ជូនគ្រប់ប្រភេទចេញ-ចូលរាជធានីភ្នំពេញ (ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយរថយន្តដឹកជញ្ជូនគ្រប់ប្រភេទក្នុងទីប្រជុំជន)។
- ជំរុញការរៀបចំសណ្ដាប់ធ្នាប់ចរាចរណ៍ និងសណ្ដាប់ធ្នាប់សាធារណៈ បើកទូលាយចរាចរណ៍លើទ្រូងផ្លូវ និងចិញ្ចើមផ្លូវ តាមដងមហាវិថីសំខាន់ៗ ទប់ស្កាត់លុបបំបាត់ការរំលោភលើទ្រូងផ្លូវ និងចិញ្ចើមផ្លូវដើម្បីផលប្រយោជន៍ផ្ទាល់(តាំងលក់ ធ្វើអាជីវកម្ម ការដ្ឋានសំណង់ផ្សេងៗ ជាចំណងយានយន្ត ផ្ញើយានយន្ត សង់រោងបុណ្យ ពិធីមង្គលការ ។ល។ បង្កភាពបាត់សណ្ដាប់ធ្នាប់ កកស្ទះចរាចរណ៍ និងបាត់ចំណែកផ្លូវសម្រាប់អ្នកថ្មើរជើងធ្វើដំណើរ។
- បំប៉នបន្ថែមសមត្ថភាពច្បាប់ និងជំនាញដល់កងកម្លាំងអនុវត្តច្បាប់នូវវិន័យ សីលធម៌ ភាពស្អាតស្អំ ស្មោះត្រង់ ទទួលខុសត្រូវចំពោះតួនាទី ភារកិច្ចសម្រេចបានល្អរាល់ភារកិច្ច។ ផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធិភាពសេចក្ដីណែនាំស្ដីពីការពង្រឹងសីលធម៌ វិន័យ និងរបៀបរបបការងាររបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក និងមន្ត្រីនគរបាលសណ្ដាប់ធ្នាប់។

### ២.៣.៤ បញ្ហាប្រឈមមួយចំនួនរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

យោងតាមឯកសារជំនួយស្មារតីដែលរៀបចំឡើងដោយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញក្នុងកិច្ចពិភាក្សាតុមូលស្ដីពី ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា និងការទទួលខុសត្រូវរបស់អ្នកបើកបរ និងការអនុវត្តច្បាប់នៅរាជបណ្ឌិត្យសភាកម្ពុជា នាថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៨ ក៏បានលើកឡើងផងដែរអំពីបញ្ហាប្រឈមមួយចំនួនចំពោះការចេញប្រតិបត្តិការរបស់ខ្លួនកន្លងមកដូចជាៈ

- ការធ្វើវិស្វកម្មផ្លូវថ្នល់នៅមិនទាន់បានឆ្លើយតបទៅនឹងការរីកចម្រើនឥតឈប់ឈរនៃវិស័យសណ្ដាប់ធ្នាប់ចរាចរណ៍(ការថែទាំ កែលម្អផ្លូវថ្នល់ កសាងស្ពាន ស្ពានអាកាស ផ្លូវរថភ្លើងលើអាកាស ផ្លូវរូងក្រោមដី ការដាក់របាំងបែងចែកទ្រូងផ្លូវ គំនូសសញ្ញាចរាចរណ៍ ការកំណត់ទិស

ចរាចរណ៍ ការបំពាក់ប្រព័ន្ធចរាចរណ៍ កាមេរ៉ាត្រួតពិនិត្យ ប្រព័ន្ធលូរទឹក ភ្លើងបំភ្លឺ ពេលយប់ជាដើម...)។

- ការអប់រំផ្សព្វផ្សាយច្បាប់មិនទាន់បានទូលំទូលាយគ្រប់ប្រព័ន្ធផ្សព្វផ្សាយគ្រប់ទីកន្លែង និងកែប្រែឥរិយាបថខ្លាចនគរបាល មកគោរពច្បាប់ចរាចរណ៍ផ្លូវគោកវិញ។
- ការរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកមិនបានអនុវត្តជាប្រចាំ គ្រប់ទីកន្លែង (ជាប់ភារកិច្ចច្រើន សភាពការណ៍នយោបាយ) មិនបានត្រួតពិនិត្យនៅចំណុចដើមទី អនុវត្តមិនអស់លទ្ធភាពនៃប្រសិទ្ធភាពច្បាប់ និងខ្វះកម្លាំងសម្រាប់ពង្រាយឲ្យបានគ្រប់ចំណុចកកស្ទះ ស្មារតីគោរពអនុវត្តច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត ការងារត្រួតពិនិត្យរថយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស មន្ត្រីជំនាញមិនមានសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើការកែសម្រួល កាត់ទ្រុងតាមលក្ខណៈបច្ចេកទេសស្តង់ដារកំណត់។
- វត្តមានរថយន្តដឹកជញ្ជូនទំនិញគ្រប់ប្រភេទ(រថយន្តធុនធ្ងន់) ធ្វើចរាចរណ៍ចេញ ចូល ឆ្លងកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ល្មើសនឹងសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ ដោយបើកបរគ្មានបណ្ណអនុញ្ញាត បើកបរខុសតម្រាយផ្លូវ និងពេលវេលាកំណត់។
- វត្តមានបណ្តាឃ្លាំង រោងចក្រ សហគ្រាស ក្រុមហ៊ុនដឹកជញ្ជូន មានទីតាំងនៅក្នុងរាជធានីភ្នំពេញ (តម្រូវការក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ និងការសាងសង់អាគារ លំនៅឋានជាដើម)។
- កង្វះការសហការចូលរួមពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលមានកាតព្វកិច្ចចូលរួមដោះស្រាយសណ្តាប់ធ្នាប់ចរាចរណ៍ឲ្យបានម៉ឺងម៉ាត់។ ការផ្តន្ទាទោសចំពោះជនប្រព្រឹត្តបទល្មើសនៅមានភាពធូររលុង បណ្តោះឲ្យជនល្មើសរួចពីសំណាញ់ច្បាប់។
- សេវាដឹកជញ្ជូនអ្នកដំណើរនៅក្នុងរដ្ឋបាលរាជធានីភ្នំពេញ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីកាត់បន្ថយមធ្យោបាយផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ ម្យ៉ាងទៀតប្រជាពលរដ្ឋមិនទាន់មានទម្លាប់ និងចំណូលចិត្តច្រើនអំពីការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសាធារណៈ។
- ការរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរតាមទ្រូងនិងចិញ្ចើមផ្លូវនៅមានលក្ខណៈដូចវែកចក។
- ទ្រូងផ្លូវមួយចំនួនត្រូវបានរំលោភ តាំងការលក់ដូរ ធ្វើអាជីវកម្ម គ្មានចំណតយានយន្ត ដាក់វត្ថុធាតុដើមរបស់ការដ្ឋាន អាគារ លំនៅដ្ឋាន លើទ្រូង-ចិញ្ចើមផ្លូវ។ល។
- ស្មារតីទទួលខុសត្រូវរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិតនៅឡើយ អសកម្ម អនុវត្តលើសពីបទបញ្ញា បង្កភាពស្មុគស្មាញ គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន និងភាពថ្នាំងថ្នាក់របស់ប្រជាពលរដ្ឋចំពោះកងកម្លាំង។

# សេចក្តីសន្និដ្ឋាន

ពិតមែនហើយក្នុងពេលបច្ចុប្បន្ននេះ បញ្ហាចរាចរណ៍បាននឹងកំពុងតែក្លាយទៅជាចំណុចអាទិភាពសម្រាប់សាលារាជធានីភ្នំពេញក្នុងការស្វែងរកដំណោះស្រាយឲ្យបានទាន់ពេលវេលា ឆ្លើយតបទៅនឹងកំណើនឥតឈប់ឈរនៃយានជំនិះគ្រប់ប្រភេទ និងអ្នកបើកបរនៅក្នុងរាជធានីភ្នំពេញ។ សម្រាប់ប្រជាពលរដ្ឋទូទៅ បញ្ហាកកស្ទះចរាចរណ៍ធ្វើឲ្យពួកគេមានអារម្មណ៍នឿយហត់និងតឹងទ្រូងជាខ្លាំង ទាំងដែលមិនដឹងថាត្រូវនឹងរៀបរាប់យ៉ាងដូចម្តេចខ្លះនោះទេ អំពីអារម្មណ៍ដែលស្ថិតនៅក្នុងការរង់ចាំទាំងមេឃក្តៅ ឬហាលទឹកភ្លៀង ឬឈរមើលបុគ្គលមួយចំនួនបើកបរដោយមិនបានគោរពទៅតាមវិធាននៃច្បាប់ចរាចរណ៍នោះ។ បញ្ហានេះវាកើតឡើងពីប្រជាពលរដ្ឋ និងភាពអវិជ្ជមានមួយចំនួនដែលយើងអាចនិយាយបានថា បណ្តាមកពីការអនុវត្តរបស់ស្ថាប័នសាធារណៈ។ ហើយម៉្យាងទៀតបើបញ្ហាកកស្ទះនេះកើតមានឡើងហើយវានាំឲ្យមានបញ្ហាជាច្រើនទៀតបានកើតឡើងជាបន្តបន្ទាប់ដូចជា ខាតពេលវេលា ខាតសេដ្ឋកិច្ចជាតិ ប៉ះពាល់ដល់កន្លែងបំពេញកិច្ចការងាររបស់ប្រជាពលរដ្ឋផ្សេងៗជាដើម។ ចំណុចវិជ្ជមានជាច្រើនបានកើតមានឡើងនៅក្នុងមួយរយៈពេលចុងក្រោយនេះ ដោយគេឃើញមាន វីឌីអូអប់រំច្រើនពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍ និងក៏ឃើញមានអ្នកចូលរួមជួយច្រើនចំពោះការអប់រំនិងផ្សព្វផ្សាយពីការបើកបរឲ្យបានត្រឹមត្រូវ និងឥរិយាបថនៃការបើកបរលើដងផ្លូវ។ ទន្ទឹមនឹងនេះផងដែរនោះ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងតែបំពេញតួនាទីក្នុងនាមជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋទាំងមូល ដែលត្រូវធ្វើយ៉ាងណាឲ្យបញ្ហាដ៏រសើបនេះត្រូវបានកាត់បន្ថយជាអតិបរមាពីមួយថ្ងៃៗ។

តាមរយៈការស្រាវជ្រាវអត្ថបទសារណាមួយក្បាលនេះ ខ្ញុំបាទពិតជាទទួលបានបទពិសោធន៍ច្រើនពាក់ព័ន្ធនឹងបញ្ហាកកស្ទះចរាចរណ៍ ព្រមទាំងបានចូលរួមចំណែកក្នុងការស្វែងយល់អំពីបញ្ហាដែលបានកើតឡើងជាក់ស្តែងនៅក្នុងសង្គមព្រមជាមួយនឹងដំណោះស្រាយដែលយើងអាចនឹងធ្វើវាបានប្រកបដោយប្រសិទ្ធិភាពនិងប្រសិទ្ធិខ្ពស់។ យើងអាចធ្វើការសន្និដ្ឋានបានថា បើទោះបីជាបញ្ហាកកស្ទះចរាចរណ៍នេះបានកើតឡើងហើយក៏ដោយ ប៉ុន្តែយើងនៅតែអាចស្វែងរកដំណោះស្រាយបានតាមរយៈការអនុវត្តឲ្យមានប្រសិទ្ធិភាពនូវច្បាប់ចរាចរណ៍ផ្លូវគោក ការសហការណ៍គ្នារវាងពលរដ្ឋនិងសមត្ថកិច្ច និងការរៀបចំមធ្យោបាយសាធារណៈឲ្យបានច្រើនតាមលទ្ធភាពដែលអាចនឹងធ្វើទៅបានសម្រាប់រាជធានីភ្នំពេញទាំងមូល។ ខ្ញុំនៅតែមានគំនិតវិជ្ជមានថា ប្រជាពលរដ្ឋនឹងបំពេញភារកិច្ចក្នុងនាមជាម្ចាស់ប្រទេសក្នុងការចូលរួមដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ដែលបានកើតឡើងជាមួយនឹងសមត្ថកិច្ចដោយស្មារតីសាមគ្គីភាព ដើម្បីឲ្យកម្ពុជាក្លាយទៅជាប្រទេសដែលមានស្ថានភាពចរាចរណ៍ល្អប្រសើរនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

# អនុសាសន៍

យោងតាមការបកស្រាយចំពោះប្រធានបទខាងលើនេះ បានបង្ហាញឲ្យឃើញពីស្ថានភាពទាំងស្រុងនៃបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញរួមជាមួយនឹងវិធានការមួយចំនួនដែលអាជ្ញាធរមានសមត្ថកិច្ចកំពុងតែមមាញឹកបំពេញការងារដោះស្រាយជូនប្រជាពលរដ្ឋ។ ដើម្បីជាការរួមចំណែកក្នុងការអភិវឌ្ឍនិងការអនុវត្តភារកិច្ចពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍នេះ ខ្ញុំបាទក្នុងនាមជាអ្នករៀបរៀង និងស្រាវជ្រាវសៀវភៅសារណាមួយក្បាលនេះ សូមលើកយកមតិយោបល់មួយចំនួនដូចតទៅ៖

- ប្រជាពលរដ្ឋគួរសហការជាមួយមន្ត្រីនគរបាលមានសមត្ថកិច្ចតាមរយៈការគោរពច្បាប់ចរាចរណ៍ ព្រមជាមួយការបើកបរដោយមានអធ្យាស្រ័យ និងទំនួលខុសត្រូវខ្ពស់
- បើកយុទ្ធការអនុវត្តច្បាប់ចរាចរណ៍ និងផ្សព្វផ្សាយជាសាធារណៈឲ្យមានប្រសិទ្ធិភាព ទាមទារដោយទទូចចំពោះអ្នកបើកបរឲ្យចូលរួមក្នុងការអនុវត្តច្បាប់ចរាចរណ៍
- អាជ្ញាធរមានសមត្ថកិច្ចត្រូវបំពេញការងារក្នុងនាមជាផលប្រយោជន៍សាធារណៈដោយក្តីពេញចិត្ត ដោយក្តីស្រលាញ់ចំពោះប្រជាពលរដ្ឋ មិនមែនតែដើម្បីប្រាក់បៀវត្សរបស់ខ្លួន
- មន្ត្រីនគរបាលគួរប្រយ័ត្នប្រយែងចំពោះអាកប្បកិរិយាក្នុងការសម្រួលចរាចរណ៍តាមដងផ្លូវ
- ព្យាយាមប្រើប្រាស់ពាក្យសម្តីឲ្យប្រជាពលរដ្ឋយល់ពីទឹកចិត្តរបស់ខ្លួនជាមន្ត្រីរាជការ និងការចូលរួមគោរពច្បាប់ចរាចរណ៍។
- ចាត់វិធានការគ្រប់បុគ្គលទាំងអស់ដែលបានបំពានលើច្បាប់ចរាចរណ៍ឬលិខិតបទដ្ឋានដែលចេញដោយរដ្ឋអំណាចដោយមិនគិតពីឋានៈ តួនាទី ភារកិច្ចអ្វីឡើយ ។
- រៀបចំផែនការអនុវត្តហើយឃ្លាំមើលមន្ត្រីនៅក្រោមឋានានុក្រមរបស់ខ្លួន ក្នុងគោលបំណងធានាឲ្យការអនុវត្តនោះទទួលបានជោគជ័យជាអតិបរមា
- លុបបំបាត់អំពើពុករលួយនៅតាមខណ្ឌនីមួយៗ ពាក់ព័ន្ធនឹងករណីអាជីវករដែលលក់ដូរនៅតាមដងផ្លូវហើយរំលោភលើផ្លូវសាធារណៈ ហើយមន្ត្រីរាជការមួយចំនួនទទួលយកលាភសក្ការៈពីការធ្វើអាជីវកម្មនោះ។
- ថ្នាក់ដឹកនាំគ្រប់អង្គភាពសាធារណៈដែលពាក់ព័ន្ធនានាគួរត្រូវបានលើកទឹកចិត្តនិងជំរុញក្នុងការរៀបចំផែនការអនុវត្តជាបន្តបន្ទាប់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

# ឯកសារយោង


## ច្បាប់

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, លេខនស/រកម/០១១៥/០០១, ០៦ មករា ២០១៥។
- ច្បាប់ស្តីពីផ្លូវថ្នល់, លេខនស/រកម/០៥១៤/០០៨, ០៤ ឧសភា ២០១៤។

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, លេខ ៨៤ អនក្រ.បក, ២១ មីនា ២០១៧។

## ផែនការ/សេចក្តីណែនាំ

- សេចក្តីណែនាំស្តីពីការដោះស្រាយចរាចរណ៍និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ០០៧/១៧ សណន.ច, ០៨ សីហា ២០១៧ ។
- ផែនការសកម្មភាព ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ, លេខ១១៤ ផ.ក, ២០ កក្កដា ឆ្នាំ២០១៧។
- ផែនការសកម្មភាពស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ, លេខ០៥០ ផ.ក, ២៥ មេសា ២០១៦។
- ផែនការស្តីពីការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវនៅរាជធានីភ្នំពេញ, ០៩ ផ.ក.ស. អណ១, ១៥ កញ្ញា ២០១៥។

## សៀវភៅ

- បណ្ឌិត អ៊ុន សក្កដា. ២០១៨. *នីតិនគរូបនីយវិទ្យារបស់បណ្ឌិត។*
- គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក. ២០១៤. *គោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក.*

## របាយការណ៍

- រដ្ឋបាលរាជធានីភ្នំពេញ. ២០១៨. *របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ.* លេខ០២០/១៨របក.រប.គ្រ. សាលារាជធានីភ្នំពេញ៖ ២៤.មករា។
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ. ២០១៧. *របាយការណ៍ស្តីពីការបូកសរុប សភាពការណ៍ កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ឆ្នាំ២០១៧.* លេខ៣៤១ រ.ប.ក. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ០៤.កក្កដា។ ដ

## គេហទំព័រ


- www.nrsc.gov.kh
- www.mpwt.gov.kh
- www.phnompenh.gov.kh
- www.interior.gov.kh
- www.presscom.gov.kh
- www.urbanvoicecambodia.net
- www.opendevelopcambodia.net
- http://www.worldbank.org
- www.opendevelopmentcambodia.net
- www.khmerload.com
- www.kohsontekpheap.com
- www.angkorpost.net
- www.Khmerpost.com

# ឧបសម្ព័ន្ធរូបភាព

## បញ្ជីឧបសម្ព័ន្ធរូបភាព

១. រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌចំការមន

២. រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌ៧មករា

៣. រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌទួលគោក

៤. រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌដូនពេញ

៥. រូបភាពមធ្យោបាយសាធារណៈ

# រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌចំការមន

១. មហាវិថីព្រះមុន្នីវ៉ង្ស :

ខាងលិចស្តុបអាងទឹកអាជីវករយកចិញ្ចើមផ្លូវដាក់តាំងសំភារៈ



ខាងលិចស្តុបអាងទឹកអាជីវករយកចិញ្ចើម និងទ្រូងផ្លូវធ្វើចំណត



ខាងកើតស្តុបអិនធីខុនអាជីវករយកទ្រូងផ្លូវប្រកបអាជីវកម្មនិងចំណត





ខាងកើតស្តុបអិនធីខុនអាជីវករយកទ្រូងផ្លូវប្រកបអាជីវកម្មនិងចំណត



ខាងកើតស្ពានអាកាសស្ទឹងមានជ័យអាជីវករយកចិញ្ចើមធ្វើជាចំណត



រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អ៊ែម_សម្បត្តិ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

ខាងកើតស្តុបអិនធីខុនអាជីវករយកចំណើមនិងទ្រូងផ្លូវធ្វើអាជីវកម្ម





ខាងកើតស្តុបអិនធីខុនអ្នករត់តាក់ស៊ីនិងឡានក្រុងយកទ្រូងផ្លូវធ្វើជាចំណត






២. ផ្លូវ ២៧១ (ស្ពានអាកាសស្ទឹងមានជ័យ ដល់ ស្ពានអាកាសក្បាលថ្នល់)






បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុំក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អេម_សម្បត្តិ

២. ផ្លូវ ២៧១ (ស្ពានអាកាសស្ទឹងមានជ័យ ដល់ ស្ពានអាកាសក្បាលថ្នល់)















បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែមិថុនាឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែមិថុនា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អែម_សម្បត្តិ















បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី..០៤..ខែ..សីហា..ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្ដាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី..០៣..ខែ..សីហា..ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្ដាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អែម_សម្បត្តិ













រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា.ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច















រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែឧសភា.ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អ៊ែម_សម្បត្តិ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី.០៤...ខែឧសភា.ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច















រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា...ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អេម_សម្បត្តិ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា...ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច















បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី.០៤..ខែសីហា.ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែសីហា.ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អ៊ែម_សម្បត្តិ









បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី.០៤..ខែសីហា.ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែសីហា.ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

៤. មហាវិថីព្រះមុនីវង្ស ( ស្តុបពេទ្យចិន ដល់ ស្ពានអាកាសក្បាលថ្នល់ )








បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា...ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា...ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អេម_សម្បត្តិ

# រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់

## ខណ្ឌ ៧មករា

### ១.ផ្លូវព្រះសីហនុ (២៧៤) និងផ្លូវនេរុហ៍ (២១៤)៖

កន្លែងលក់ម៉ូតូគីរីរម្យ យកចិញ្ចើមផ្លូវប្រកបអាជីវកម្ម




បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី.០៤..ខែសីហា ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែសីហា ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

ចំណាចខាងត្បូងស្ពានអូឡាំពិកក្រុមហ៊ុនឡានក្រុងយកទ្រូងផ្លូវធ្វើចំណត





ចំណុចផ្លូវនេះហើកន្លែងលក់រថយន្តយកចិញ្ចើមផ្លូវ និងទ្រូងផ្លូវធ្វើអាជីវកម្ម









បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី.០៤..ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣..ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

ចំណុចខាងលិចស្ពានអូឡាំពិក កន្លែងលក់ផ្លែឈើយកចិញ្ចើមផ្លូវនិងទ្រូងផ្លូវធ្វើចំណតឡាន





ខាងកើតផ្សារដេប៉ូផ្សារយកចិញ្ចើមផ្លូវ និងទ្រូងផ្លូវផ្ញើរម៉ូតូ រថយន្ត







__២.មហាវិថីព្រះមុន្នីវង្ស (ពីកែង ២៧៤ ដល់កែងមហាវិថីសហព័ន្ធរុស្សី)__






បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

## ២.មហាវិថីព្រះមុន្នីវង្ស (ពីកែង ២៧៤ ដល់កែងមហាវិថីសហព័ន្ធរុស្ស៊ី)











រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អ៊ឹម_សម្បត្តិ

បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី.០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

## ៣.មហាវិថីឧកញ៉ាទេពផន (១៨២)

ខាងត្បូងផ្សារអូរឬស្សីយកទ្រូងផ្លូវធ្វើចំណត




តុកតុកយកទ្រូងផ្លូវធ្វើជាចំណត




តុកតុកយកទ្រូងផ្លូវធ្វើជាចំណត



កន្លែងលក់ម៉ូតូយកចិញ្ចើមផ្លូវធ្វើអាជីវកម្ម



ក្រុមហ៊ុនឡានក្រុងកាពីតូលយកទ្រូងផ្លូវធ្វើចំណតអាជីវកម្ម



អាជីវករយកចិញ្ចើមផ្លូវធ្វើអាជីវកម្ម



បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្ដាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្ដាប់ធ្នាប់**

វរសេនីយ៍ឯក.អ៊ែម_សម្បត្តិ

អាជីវករយកចិញ្ចើមផ្លូវធ្វើអាជីវកម្ម



ខាងកើតផ្សារអូរឬស្សីរថយន្តចតច្រើនជួរ



ឡានដឹកទំនិញចតសាងទំនិញលើទ្រូងផ្លូវ



រថយន្តចតលើទ្រូងផ្លូវច្រើនជួរ







បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំអេច

រាជធានីភ្នំពេញ, ថ្ងៃទី.០៣..ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អែម_សម្បត្តិ

រថយន្តចតលើទ្រូងផ្លូវច្រើនជួរ




រថយន្តធុនធំចតលើទ្រូងផ្លូវសាងទំនិញ



<u>៤.មហាវិថីកម្ពុជាក្រោម (១២៨)</u>

ខាងលិចស្តុបមន្ទីរវង្សតុកតុកយកកន្លែងហាមចតធ្វើជាចំណត




ទល់មុខភោជនីយដ្ឋានថ្មដាតុកតុកយកកន្លែងហាមចតធ្វើជាចំណត




ទល់មុខមន្ទីរពេទ្យសម្ភពបញ្ញាអាជីវករយកកន្លែងហាមចតធ្វើអាជីវកម្ម



អាជីវករយកកន្លែងហាមចតធ្វើចំណត



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ... ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ... ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អេម_សម្បត្តិ

## ៤.មហាវិថីព្រះមុន្នីវង្ស (២១៧)

ខាងលិចស្តុបមុន្នីវង្សអាជីវករយកចិញ្ចើមផ្លូវធ្វើជាចំណតឡានរ



អាជីវករយកទ្រូងផ្លូវជិតស្តុបធ្វើចំណតរថយន្ត



អាជីវករយកទ្រូងផ្លូវជិតស្តុបធ្វើចំណតរថយន្ត



អាជីវករយកចិញ្ចើមផ្លូវធ្វើចំណតម៉ូតូ




ខាងកើតស្តុបនាងគង្ហីញសាលារៀនយកទ្រូងផ្លូវធ្វើជាចំណត



ខាងកើតស្តុបនាងគង្ហីញសាលារៀនយកទ្រូងផ្លូវធ្វើជាចំណត



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

# រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌទួលគោក

## ១.មហាវិថីមៅសេទុង

ខាងត្បូងស្តុបទេពផនកន្លែងលក់ឡានយកចិញ្ចើមផ្លូវដាក់តាំងរថយន្ត





ខាងត្បូងស្តុបទេពផនអាជីវករយកចិញ្ចើមផ្លូវធ្វើជាចំណត



ខាងលិចមជ្ឈមណ្ឌលម៉ុងឌីយាល់អាជីវករយកចិញ្ចើមផ្លូវធ្វើអាជីវកម្ម



ខាងលិចមជ្ឈមណ្ឌលម៉ុងឌីយាល់អាជីវករយកចិញ្ចើមផ្លូវធ្វើអាជីវកម្ម



ខាងត្បូងស្តុបកោសដ្ឋងគុកគុកបានយកទ្រូងផ្លូវធ្វើជាចំណតរងចាំ



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី.០៤...ខែឧសភា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី.០៣...ខែឧសភា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

ខាងត្បូងស្តុបកោសផ្ទង់តុកតុកបានយកទ្រូងផ្លូវធ្វើជាចំណតរងចាំ



ខាងជើងស្តុបផ្សារដើមគរអាជីវករយកចីញ្ចើមផ្លូវធ្វើអាជីវកម្ម



ខាងជើងស្តុបផ្សារដើមគរអាជីវករនិងតុកតុកយកទ្រូងផ្លូវចីញ្ចើមផ្លូវធ្វើអាជីវកម្ម






ខាងជើងស្តុបផ្សារដើមគរអាជីវករយកចីញ្ចើមផ្លូវធ្វើចំណត




ខាងត្បូងស្តុបផ្សារដើមគរប្រជាពលរដ្ឋនិងតុកតុកចតលើទ្រូងផ្លូវហាមចត



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី...០៤...ខែ...សីហា...ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំអេច

រាជធានីភ្នំពេញ,ថ្ងៃទី...០៣...ខែ...សីហា...ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

Em Sambath

វរសេនីយ៍ឯក.អេម_សម្បត្តិ

ខាងត្បូងស្តុបផ្សារដើមគរតុកតុកយកទ្រូងផ្លូវធ្វើជាចំណតរងចាំ





ខាងត្បូងផ្សារដើមគរតាក់ស៊ីនិងតុកតុកយកទ្រូងផ្លូវធ្វើចំណត





ខាងជើងស្តុបផ្សារដើមគរអាជីវករនិងតុកតុកយកទ្រូងផ្លូវនិងចិញ្ចើមផ្លូវធ្វើអាជីវកម្ម





បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

ខាងជើងស្តុបផ្សារដើមគរប្រជាពលរដ្ឋចតលើទ្រូងផ្លូវដែលហាមចត



ខាងត្បូងស្តុបកោសដ្ឋងអាជីវករយកទ្រូងផ្លូវនិងចិញ្ចើមធ្វើអាជីវកម្មនិងចំណត



ខាងលិចរបងមជ្ឈមណ្ឌលម៉ុងឌីយ៉ាល់អាជីវករយកចិញ្ចើមផ្លូវនិងទ្រូងផ្លូវធ្វើអាជីវកម្មនិងចំណត










បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី០៤...ខែ[illegible]ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំអេច

រាជធានីភ្នំពេញ,ថ្ងៃទី០៣..ខែ[illegible]ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អែម_សម្បត្តិ

២. ផ្លូវ ២៧១ (ពីផ្លូវទេពផនដល់ ស្ពានអាកាសស្ទឹងមានជ័យ)















បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អ៊ែម_សម្បត្តិ









៣. មហាវិថីមៅសេទុង (ស្តុបទេពផន ដល់ អង់តែនទួលគោក)





បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ,ថ្ងៃទី០៤...ខែសីហាឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៣..ខែសីហាឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ








បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី.០៤...ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ








រាជធានីភ្នំពេញ,ថ្ងៃទី០៣...ខែសីហា ឆ្នាំ២០១៦

**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ,ថ្ងៃទី០៤...ខែសីហា ឆ្នាំ២០១៦

**ស្នងការរង ទទួលដឹកនាំ**

**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

# រូបភាព និងគោលដៅរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌដូនពេញ

**មហាវិថីព្រះមុន្នីវង្ស**

មុខពេទ្យកាល់ម៉ែតប្រជាពលរដ្ឋចតនៅលើទ្រូងផ្លូវមានផ្លាកហាមចត និងគំនូសសញ្ញាសំរាប់ថ្មើរជើងឆ្លងកាត់ផ្លូវ








បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី.០៤.ខែ.សីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី.០៣.ខែ.សីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

មុខវិទ្យាស្ថានបាស្ទឺរអាជីវករយកចិញ្ចើមផ្លូវនិងទ្រូងផ្លូវធ្វើជាចំណត



ចំណុចផ្លូវចូលសណ្ឋាគារន្ទីពេញគាក់ស៊ី និងតុកតុកបានចតលើទ្រូង និងចិញ្ចើមផ្លូវ



ចំណុចផ្លូវចូលសណ្ឋាគារន្ទីពេញគាក់ស៊ី និងតុកតុកបានចតលើទ្រូង



និងចិញ្ចើមផ្លូវមុខវិទ្យាស្ថានពេទ្យប្រជាពលរដ្ឋចតលើចិញ្ចើមផ្លូវ



មុខធនាគារអេសីលីដាប្រជាពលរដ្ឋចតលើគំនូសថ្មើរជើងឆ្លងកាត់ផ្លូវ



បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី..០៤..ខែសីហា.ឆ្នាំ២០១៦
**ស្នងការរង ទទួលដឹកនាំ**
**ការងារការិយាល័យនគរបាលសណ្តាប់ធ្នាប់**

ឧត្តមសេនីយ៍ត្រី.អ៊ុក_សំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៣...ខែសីហា.ឆ្នាំ២០១៦
**នាយការិយាល័យនគរបាលសណ្តាប់ធ្នាប់**

វរសេនីយ៍ឯក.អេម_សម្បត្តិ

# រូបភាពមធ្យោបាយសាធារណៈ













# ឧបសម្ព័ន្ធគតិយុត្ត

## បញ្ជីឧបសម្ព័ន្ធគតិយុត្ត

១. ផែនការស្តីពីការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវនៅរាជធានីភ្នំពេញ ឆ្នាំ២០០៩

២. ផែនការសកម្មភាពស្តីពីការរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅរាជធានីភ្នំពេញ ឆ្នាំ២០១៥

៣.ឧបសម្ព័ន្ធចំណុចកកស្ទះនៅរាជធានីភ្នំពេញ ឆ្នាំ២០១៦

៤. ផែនការសកម្មភាព ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៦

៥. អនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៧

៦. សេចក្តីណែនាំស្តីពី ការដោះស្រាយចរាចរណ៍ និងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញឆ្នាំ២០១៧

៧. សេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញឆ្នាំ២០១៧

៨. ផែនការសកម្មភាព ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧

៩. របាយការណ៍បូកសរុប សភាពការណ៍ កិច្ចប្រតិបត្តិ-រក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧

១០. សេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការរៀបចំសណ្តាប់ធ្នាប់សាធារណៈក្នុងរាជធានីភ្នំពេញ

១១. ជំនួយស្មារតីក្នុងកិច្ចពិភាក្សាតុមូល ស្តីពី ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា និងការទទួលខុសត្រូវរបស់អ្នកបើកបរ និងការអនុវត្តច្បាប់នៅរាជបណ្ឌិត្យសភាកម្ពុជាឆ្នាំ២០១៨។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

លេខ : ០៩ ផក.ស.គណ១

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

ចូល ថ្ងៃទី១៣ខែ ៩ ឆ្នាំ២០០៩

ម៉ោង ... បរ. ... បរា

បញ្ជូន.....................

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩

## ផែនការ

## ស្តីពី ការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវនៅរាជធានីភ្នំពេញ

---

<u>យោង</u> : -ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

-ផែនការលេខ ០៣៦ ផក/គបចគ. ចុះថ្ងៃទី ០៣-៨-២០០៩ របស់គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ។

-លិខិតលេខ ០៥៣ សណន/គបចគ ចុះថ្ងៃទី ១៧-០៨-២០០៩ របស់គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ។

ដើម្បីទប់ស្កាត់ កាត់បន្ថយ ឈានទៅលុបបំបាត់គ្រោះថ្នាក់ចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ តាមដងផ្លូវនៅរាជធានីភ្នំពេញឱ្យបានល្អប្រសើរ គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ ផ្លូវគោកថ្នាក់រាជធានីភ្នំពេញ ដាក់ចេញនូវផែនការ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវនៅរាជធានីភ្នំពេញ ដូចខាងក្រោម :

### I.គោលបំណង_សំណុមពរ :

-លុបបំបាត់ការដាក់លក់ដូរ ឬ វត្ថុផ្សេងៗ លើចិញ្ចើមផ្លូវ ដែលបង្កការរាំងស្ទះដល់ការធ្វើដំណើររបស់អ្នកថ្មើរជើង ។

-លុបបំបាត់ការដាក់លក់លើជាយផ្លូវ ដែលនាំឱ្យបាត់សណ្តាប់ធ្នាប់ និងបង្កការរាំងស្ទះចរាចរ ។

-បង្កើនប្រសិទ្ធិភាពមន្ត្រីអនុវត្តច្បាប់ ដោយពង្រឹងវិន័យ សីលធម៌ អកប្បកិរិយាសុភាពរាបសារ ម៉ត់ចត់ តែម៉ឺងម៉ាត់ ក្នុងការបំពេញតួនាទីភារកិច្ច ទទួលបានការគាំទ្រពីប្រជាពលរដ្ឋ ។

-បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ពីការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈ ។

### II.វិធានការដាក់ស្តែង:

ដើម្បីធានាការរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយល្អ ត្រូវមានវិធានការម៉ឺងម៉ាត់ដូចខាងក្រោម :

**១-ទ្រូងផ្លូវ : ត្រូវលុបបំបាត់ការប្រើប្រាស់ទ្រូងផ្លូវមិនត្រឹមត្រូវដូចជា :**

-ការយកវត្ថុផ្សេងៗ យកទៅដាក់លើទ្រូងផ្លូវដូចជា ឧបករណ៍សម្ភារៈសំណង់ កាកសំណល់ផ្សេង ៗ...

-ការចតឈប់យានជំនិះ ច្រើនជួរ



៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣-៧២២ ៧៣៥ / ៧២៨ ...

-ការចតយានជំនិះលើទ្រូងផ្លូវច្រាសទិសចរាចរណ៍

-ការចតយានជំនិះ នៅចំណោចផ្លូវប្រសព្វ ជាពិសេសនៅកន្លែងភ្លើងស្តុប

-ការយកទ្រូងផ្លូវធ្វើជាចំណតរថយន្ត និងយានជំនិះគ្រប់ប្រភេទ

-ការកាប់គាស់ និងជួសជុលទ្រូងផ្លូវគ្មានសណ្តាប់ធ្នាប់

-មានវិធានការទបស្កាត់ កាត់បន្ថយ និងឈានទៅលុបបំបាត់ការសាងសង់រោងបុណ្យ ឬ ពិធីផ្សេង ៗ

-ការលែងសត្វពាហនៈឱ្យដើររហេតរហូត

-ការប្រើប្រាស់ផ្លូវគ្មានការថែទាំ ។

**២-ចិញ្ចើមផ្លូវ : ត្រូវលុបបំបាត់ការប្រើប្រាស់ចិញ្ចើមផ្លូវមិនត្រឹមត្រូវដូចជា :**

-ការចតយានជំនិះគ្មានសណ្តាប់ធ្នាប់

-ការតាំងលក់ឧបករណ៍សម្ភារៈសំណង់រំលោភលើផ្លូវរបស់ថ្មើរជើង

-ការសាងសង់សំណង់ផ្សេង ៗ រំលោភលើចិញ្ចើមផ្លូវ

-ការប៉ះពាល់ដល់គំហើញរបស់អ្នកបើកបរ ដែលបង្កដោយដើមឈើ និងវត្ថុផ្សេង ៗ

-ការកាប់គាស់ និងជួសជុលចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់

-ការរំលោភយកចិញ្ចើមផ្លូវមកប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់មុខ ដូចជាដាក់ផ្លាកសញ្ញាហាមចត ដាក់របាំង យកជាកន្លែងធ្វើអាជីវកម្មលក់ដូរ ឬ ផ្ញើយានជំនិះផ្សេង ៗ

-ការដាំដើមឈើគ្មានសណ្តាប់ធ្នាប់តាមចិញ្ចើមផ្លូវ ឬ គំរបលូ

-ការសាងសង់ចិញ្ចើមផ្លូវទាបខ្ពស់ដែលបង្កការលំបាកដល់អ្នកថ្មើរជើង ។

ដើម្បីអនុវត្តនូវចំណុចទី១ និងទី២ ឱ្យមានប្រសិទ្ធិភាព រដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ច នគរបាល កងរាជអាវុធហត្ថ ត្រូវចាត់វិធានការជូនដំណឹង អប់រំ មានវិធានការរដ្ឋបាល ឬ វិធានការច្បាប់ ដើម្បីលុបបំបាត់ការប្រើប្រាស់ទ្រូងផ្លូវ និងចិញ្ចើមផ្លូវមិនត្រឹមត្រូវ ។

## III.សំពីការអនុវត្ត :

-រៀបចំសណ្តាប់ធ្នាប់ ការលក់ដូរលើចិញ្ចើមផ្លូវសាធារណៈ នៅតាមបណ្តាផ្លូវសំខាន់ៗ មួយចំនួនក្នុងរាជធានីភ្នំពេញដូចជា : ផ្លូវព្រះមុនីវង្ស ផ្លូវកម្ពុជាក្រោម ផ្លូវម៉ៅសេទុង ផ្លូវព្រះសីហនុ ផ្លូវហ្សាដឺហ្គោល ផ្លូវសុខហុក (ផ្លូវលេខ ១០៧) ផ្លូវមុនីរេត ផ្លូវជាតិលេខ ១ ( ចំណុចតលស្ពានព្រះមុនីវង្សត្រើយខាងកើត ) ផ្លូវជាតិលេខ ២ ( ពីរង្វង់មូលក្បាលថ្នល់រហូតដល់រង្វង់មូលព្រះនរាយ៍ខេត្តកណ្តាល ) ។

-រៀបចំសណ្តាប់ធ្នាប់ការលក់ដូរនៅតាមមុខរោងចក្រកាត់ដេរនានា នៅក្នុងខណ្ឌក្រៅរាជធានី ( ខណ្ឌមានជ័យ សែនសុខ ដង្កោ និងឬស្សីកែវ ) ដើម្បីកុំឱ្យកកស្ទះចរាចរ ពេលម៉ោងកម្មករចេញ-ចូលធ្វើការ ។

-រៀបចំសណ្តាប់ធ្នាប់ចំណតរថយន្តទាំងក្នុង និងក្រៅរាជធានីភ្នំពេញ មានចំណតផ្សារធំថ្មី ចំណតផ្សារអូរឬស្សី ចំណតផ្សារអូឡាំពិក ចំណតច្រាំងចំរេះ ចំណតចោមចៅ ចំណតផ្លូវជាតិលេខ២ ចំណត ច្បារអំពៅ...។ល។

-រៀបចំសណ្តាប់ធ្នាប់ការដាក់តាំងលក់គ្រឿងសំណង់ ទូរស័ព្ទសាធារណៈ ការដាក់តាំងលក់សាំង និងផ្លែឈើ លើចិញ្ចើមផ្លូវដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។

-រៀបចំសណ្តាប់ធ្នាប់នៅបរិវេណវត្តអារាមសំខាន់ៗ មួយចំនួនដូចជា ( វត្តលង្កា វត្តឧណ្ណាលោម វត្តព្រះពុទ្ធ...) កន្លែងសក្ការៈបូជា ( ព្រះអង្គដងកើមុខព្រះបរមរាជវាំង ) រមណីយដ្ឋានវត្តភ្នំ និងសួនកំសាន្តនានា ។

-ការដាក់តាំងតុ កៅអី សំរាប់លក់គ្រឿងក្លែម គ្រឿងហូបចុកនៅតាមអាហារដ្ឋាននានា និងការចតឥតសណ្តាប់ធ្នាប់នៅតាមភោជនីដ្ឋាន ផ្ទះសំណាក់ និងសណ្ឋាគារ ។

-រៀបចំសណ្តាប់ធ្នាប់ការលក់ដូរនៅមុខផ្សារនានា ក្នុងរាជធានីភ្នំពេញ ។

## IV.អំពីភារកិច្ច និងការទទួលខុសត្រូវ :

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង ០៨ ត្រូវសហការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវក្នុងរាជធានីភ្នំពេញឱ្យបានល្អប្រសើរ ។

-ការរៀបចំសណ្តាប់ធ្នាប់លើទ្រូងផ្លូវ ប្រគល់ភារកិច្ចឱ្យការិយាល័យសណ្តាប់ធ្នាប់សាធារណៈ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញជាអ្នកទទួលខុសត្រូវ និងចាត់ចែងរៀបចំឱ្យបានល្អ ដើម្បីកុំឱ្យមានការកកស្ទះចរាចរ ។

-ការរៀបចំសណ្តាប់ធ្នាប់លើចិញ្ចើមផ្លូវ ការលក់ដូរ និងការដាក់តាំងវត្ថុផ្សេងៗ លើចិញ្ចើមផ្លូវ ប្រគល់ភារកិច្ចឱ្យសង្កាត់ និងខណ្ឌសហការជាមួយនគរបាលប៉ុស្តិ៍ និងអធិការដ្ឋាននគរបាលខណ្ឌ ជាអ្នកទទួលខុសត្រូវ និងចាត់ចែងរៀបចំសណ្តាប់ធ្នាប់ឱ្យបានល្អ ដើម្បីឱ្យអ្នកថ្មើរជើងអាចធ្វើដំណើរបាន ។

-ស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ និងសាលាខណ្ឌទាំង៨ ត្រូវចាត់តាំងក្រុមចំរុះមួយ សំរាប់ចុះល្បាតត្រួតពិនិត្យសកម្មភាពល្មើសនានា ដែលកើតមានឡើងនៅក្នុងរាជធានីភ្នំពេញ ដោយធ្វើការស្តីបន្ទោស និងផាកពិន័យចំពោះរថយន្តដែលល្មើសច្បាប់ ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងសាលាខណ្ឌទាំង៨ ត្រូវធ្វើការផ្សព្វផ្សាយផែនការនេះ ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹង និងចូលរួមអនុវត្តនូវផែនការនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ត្រូវបូកសរុបរាយការណ៍ប្រចាំថ្ងៃ សប្តាហ៍ និងខែ ជូនលេខាធិការដ្ឋានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីលេខាធិការដ្ឋានរៀបចំដាក់ជូនគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកជ្រាប និងសុំមតិដឹកនាំបន្ត ។

## V.អំពីការចាត់តាំងអនុវត្ត :

ដើម្បីធានាអនុវត្តឱ្យមានប្រសិទ្ធិភាពនូវផែនការនេះ គណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ សំរេចចាត់តាំងមន្ត្រីដូចតទៅ :-

| | | | |
|---|---|---|---|
| ១-លោក | ម៉ាន់ ឈឿន | អភិបាលរងរាជធានីភ្នំពេញ | ប្រធាន |
| ២-លោក | អែល សំនាង | ស្នងការរងនគរបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣-លោក | គង់ គីនី | មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានីភ្នំពេញ | អនុប្រធាន |
| ៤-លោក | ខៀវ សារុន | អនុប្រធានមន្ទីរសាធារណៈការនិងដឹកជញ្ជូនរាជធានីភ្នំពេញ | អនុប្រធាន |
| ៥-លោក | សុខ ធឿន | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |

៦-លោក កើត រ័ធ នាយរងខុទ្ទកាល័យសាលារាជធានីភ្នំពេញ សមាជិក

៧-លោក ខាំពូន កែវមុណី អគ្គនាយកវិទ្យុ និងទូរទស្សន៍រាជធានីភ្នំពេញប៉ុស្តិ៍លេខ៣ សមាជិក

៨-លោកអភិបាលរងទទួលសណ្តាប់ធ្នាប់ខណ្ឌទាំង ០៨ សមាជិក

៩-លោក ហាស តិរម្យ នាយការិយាល័យសណ្តាប់ធ្នាប់សាធារណៈ សមាជិក

១០-លោក អ៊ាន សុឃីម អនុប្រធានការិយាល័យសរុប សមាជិក

១១-លោក គាំង ឈាងគ្រី មន្ត្រីការិយាល័យសរុប សមាជិក

១២-លោក អេង សេតស៊ីម៉ា មន្ត្រីការិយាល័យសរុប សមាជិក

ទទួលបានផែនការនេះ នាយខុទ្ទកាល័យសាលារាជធានីភ្នំពេញ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងមន្ទីរពាក់ព័ន្ធ ត្រូវលើកកំពស់ស្មារតីទទួលខុសត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានគណៈបញ្ជាការដឹកនាំ បញ្ជា ត្រួតពិនិត្យ

ការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ

កែប ជុតិមា

*កន្លែងទទួល :*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងសាធារណៈការ និងដឹកជញ្ជូន*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *អគ្គស្នងការដ្ឋាននគរបាលជាតិ*
- *បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*
- *ក្រុមប្រឹក្សារាជធានីភ្នំពេញ*

*ដើម្បីជូនប្រាប*

- *ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ*
- *បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ*
- *សាលាខណ្ឌទាំង ៨*
- *មន្ទីរសាធារណៈការនិងដឹកជញ្ជូនរាជធានីភ្នំពេញ*
- *មន្ទីរព័ត៌មានរាជធានីភ្នំពេញ*

*ដើម្បីអនុវត្ត*

- *ឯកសារ-កាលប្បវត្តិ*